Jesus' parting instruction in Matthew was to make disciples, teaching converts to obey all he had commanded. Our obedience to that commission remains incomplete if we have not taught at least one—by our words, examples, and supervision of his efforts—to carry on and extend the work after we are gone.

There are pastors who busily preach, teach, travel to other venues, chair committees, and serve in many important ways, yet who do this basically by themselves. They may be consider it a compliment when others say, "Pastor, no one can do these things as well as you!" When such a leader dies or moves on, the church or organization he led often takes a nosedive because of a sudden vacuum in leadership and expertise. Others may unthinkingly remark, "Wasn't he a great leader? No one else is as good as he was. Things are falling apart without him." But does falling apart indicate success or failure? Is not a measure of our success whether what we have done survives us, whether others have been empowered to continue and advance our work? Is ministry about our personal success, or the church's success?

សំណុំទឹកឃ្មុំ ២/៣ (កក្កដា ២០០១)៖ ៧២-៩៣



# ជោគជ័យ និង អ្នកបន្តវេន

រ៉ាស់សែល បាវើស៍

## តើយើងវាស់ការទទួលជោគជ័យដោយរបៀបណា?

តើយើងយកគំរូមាត្រដ្ឋានណា ដែលយើងអាចវាស់ថា មនុស្សណាម្នាក់បានទទួលជោគជ័យនៅក្នុងព័ន្ធកិច្ចបំរើព្រះ?

តើសំអាងលើហ្វូងមនុស្សច្រើនមកស្តាប់ ការបង្រៀនរបស់មនុស្សណាម្នាក់ និង បង្ហាញទីសំគាល់នៃឥទ្ធិពលរបស់សេចក្តីបង្រៀននោះឬ? ព្រះយេស៊ូបានធ្វើឲ្យមានការទាក់ទាញហ្វូងមនុស្សជាច្រើន កាលពីដំណាក់កាលដំបូងនៃព្រះរាជព័ន្ធកិច្ចរបស់ព្រះអង្គ ។ ព្រះអង្គជ្រាបពី "ជំនឿ" សើៗរបស់ពួកហ្វូងមនុស្ស ទើបព្រះអង្គបានបណ្តោយពួកគេចេញ ដោយទុកតែអ្នកដែលជំនឿប្តូរផ្តាច់តាមព្រះអង្គតែប៉ុណ្ណោះ ។[១]

ទេ ចំនួនមនុស្សមិនបង្ហាញថា បានទទួលជោគជ័យនោះឡើយ នៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់ ។ ចំពោះរឿងរ៉ាវដទៃទៀតក៏ដូចគ្នានេះដែរ យើងជាធម្មតាតែងតែចង់ឃើញមនុស្សជាច្រើនឆ្លើយតបមកយើង

---

[១] សូមមើល យ៉ូហាន ៦:១៤-១៥ និង ការដែលព្រះយេស៊ូដកថយ ។ នៅខាងចុងនៃជំពូកនេះ សិស្សរបស់ព្រះអង្គជាច្រើនងាកបែរចេញពីការដើរតាមព្រះអង្គ (ខ ៦៦) ។ បន្ទាប់មកនៅក្នុង យ៉ូហាន ៨:៣១ ព្រះយេស៊ូបានបង្រៀនដល់ពួកសាសន៍យូដា ដែលបានជឿដល់ព្រះអង្គប្រកាន់ខ្ជាប់នូវសេចក្តីបង្រៀនរបស់ព្រះអង្គ បើសិនជាគេចង់រួចខ្លួន ។ យោងតាម ខ ៥៩ ពួកគេរើសដុំថ្មចង់គប់ព្រះយេស៊ូសម្លាប់ចោល ។

វិញ គឺមិនចង់ឃើញមនុស្សតិចនោះឡើយ ដែលប្រកាសពីភាពស្មោះស្ម័គ្រចំពោះព្រះគ្រីស្ទ និង ព្រមចូលរួមជាមួយនឹងក្រុមជំនុំ ។ ប៉ុន្តែបើសិនជាពួកគេបានធ្វើដូច្នេះ ដោយព្រោះតែមានហេតុផលមិនស៊ីជម្រៅដូចមានចែងនៅក្នុងយ៉ូហាន ជំពូក ៦ ឬ ដោយមិនមានការចុះចូលដល់ព្រះបន្ទូលរបស់ព្រះអង្គ ដូចដែលព្រះយេស៊ូ បានបង្គាប់នៅក្នុងយ៉ូហាន ជំពូក ៨ ចំនួនមនុស្ស ដែលមកតាមយើងមិនមែនបានន័យថាជាចំនួនមនុស្ស ដែលយើងបានឈ្នះនោះឡើយ តែគឺបង្ហាញពីចំនួនដែលយើងទទួលបរាជ័យទៅវិញទេ ។

តើយើងគួរនិយាយថា ការទទួលបានជោគជ័យនោះគឺ វាស់បានដោយសារភាពស្មោះស្ម័គ្រផ្ទាល់ខ្លួនរបស់អ្នកបំរើព្រះ ចំពោះព្រះអម្ចាស់ និង ព្រះបន្ទូលរបស់ព្រះអង្គ ដោយមិនគិតដល់ថា តើមនុស្សបានឆ្លើយតបទៅនឹងសេចក្ដីបង្រៀននោះឬអត់? ពិតមែនហើយ ការនេះតំណាងឲ្យលើសពីរង្វាស់ផ្នែកខាងវិញ្ញាណទៅទៀត ។ លោកប៉ូលបានប្រាប់ដល់ក្រុមជំនុំនៅក្នុងក្រុងកូរិនថូសថាគឺ ជាតម្រូវការចំពោះអស់អ្នកណា ដែលគេបានផ្ដល់នូវការទុកចិត្តនោះ ត្រូវតែបង្ហាញពីភាពស្មោះស្ម័គ្រ" នោះទៅដល់អ្នកដែលបានប្រគល់ការងារឲ្យគេធ្វើនោះ ។ ហេតុដូច្នេះហើយគាត់មិនខ្វល់ថា តើមនុស្សម្នាឲ្យតម្លៃគាត់របៀបណានោះឡើយ[២] ។ ព្រះជាម្ចាស់បានមានបន្ទូលទៅព្យាការីអេសេគាល ឲ្យប្រកាសព្រះបន្ទូលរបស់ព្រះអង្គយ៉ាងស្មោះស្ម័គ្រប្រាប់ដល់សាសន៍យូដាទោះបីគេព្រមស្ដាប់ឬមិនព្រមស្ដាប់នោះឡើយ ។ តាមពិតទៅគាត់បានបង្ហាញឲ្យដឹងយ៉ាងច្បាស់ថាពួកគេនឹងមិនព្រមស្ដាប់ឡើយ ។ តែទោះបីជាយ៉ាងណាក៏ដោយលោកអេសេគាលនៅតែប្រកាសប្រាប់តែដដែលហ្នឹង[៣] ។ ព្រះយេស៊ូបានប្រកាស

---

[២] *១កូរិនថូស ៤:២-៣ និង បន្តបន្ទាប់មកទៀត*

[៣] *អេសេគាល ២-៣*

ហៅពីរដង "ស្មរបន្ទាល់ដ៏ស្មោះត្រង់"[៤] និងអស់អ្នកណាដែលព្រះអង្គប្រទានរង្វាន់ឲ្យនៅពេលព្រះអង្គយាងត្រឡប់មកវិញ គឺជា "បាវដ៏ល្អ និង ស្មោះត្រង់" របស់ព្រះអង្គ[៥] ។ ដូច្នេះភាពស្មោះត្រង់ នោះគឺត្រូវមានលក្ខណវិនិច្ឆ័យយ៉ាងច្បាស់លាស់ សំរាប់ការទទួលជោគជ័យនៅចំពោះព្រះអម្ចាស់ ។

តើយើងអាចស្ទង់មើល ការនេះឲ្យបានជ្រៅជាងនេះបន្តិចបានទេ? គ្រឹះសំខាន់នៃភាពស្មោះត្រង់ គឺជាភាពសច្ចៈទៀងត្រង់ ។ ភាពស្មោះត្រង់ស្តែងចេញមកឲ្យឃើញនៅក្នុងការងារ ដែលយើងបានទទួលពីព្រះអង្គនោះ គឺមិនគ្រប់គ្រាន់ទេ បើសិនជាដួងចិត្តរបស់យើងនៅតែមិនរាយមាយនោះ ។ ព្រះគ្រីស្តដែលទទួលបានការលើកតម្កើងនោះ បានព្រមានដល់ក្រុមជំនុំដ៏ស្មោះត្រង់មួយ ដែលខំធ្វើការយ៉ាងមមាញឹក នៅឯក្រុងអេភេសូថា ក្រុមជំនុំនោះអាចនឹងបាត់បង់ឋានៈរបស់ខ្លួនជាស្មរបន្ទាល់ "ជើងចង្កៀង")បានពីព្រោះបានលះបង់ចោលនូវក្តីស្រឡាញ់ដំបូងរបស់ខ្លួន[៦]។ ព្រះជាម្ចាស់មិនបានស្វែងរកមនុស្សយន្ត ដែលរៀនច្រើន អធិប្បាយច្រើន និង ខំបំរើព្រះជាម្ចាស់ច្រើននោះឡើយ ។ ដំបូងព្រះអង្គស្វែងរកនូវសេចក្តីស្រឡាញ់ ភាពសច្ចៈទៀងត្រង់ និង សេចក្តីស្មោះត្រង់ នៃដួងចិត្ត ដែលបង្ហាញឲ្យឃើញនូវការទាំងអស់នោះ តាមរយៈភាពស្មោះស្ម័គ្រនៃការប្រព្រឹត្តិ ។ សហគមន៍គ្រីស្តបរិស័ទមិនត្រូវអនុញ្ញាតឲ្យអ្នកដឹកនាំរបស់ខ្លួនមានចរិតលក្ខណៈឃ្លាតឆ្ងាយពីការប្រព្រឹត្តិ ។ ចាស់ទុំជំនួយត្រូវតែមានចរិតលក្ខណៈដ៏ល្អសមរម្យ មុននឹងគេបំរើការងារ ដែលគេ

---

[៤] *វិវរណៈ ១:៥; ៣:១៤*

[៥] *ម៉ាថាយ ២៥:២១, ២៣*

[៦] *វិវរណៈ ២:៤ ចូរកត់សំគាល់ពីភាពស្មោះត្រង់របស់ពួកជំនុំនៅក្នុងការងាររបស់ខ្លួននៅក្នុងជំពូក ២:២-៣ ។*

សមនឹងបំរើ[៧] តែផ្ទុយទៅវិញអ្នកដែលមិនកោតខ្លាចព្រះ គេគ្មានសិទ្ធិផ្សាយព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ[៨] ។ មនុស្សណាម្នាក់ ដែលគ្មានភាពសច្ចៈទៀងត្រង់នោះ មិនអាចបង្ហាញថា បានទទួលជោគជ័យនៅក្នុងការងាររបស់ព្រះជាម្ចាស់បានឡើយ ។

តើយើងបាននិយាយអ្វីតាំងពីដើមមកទល់ពេលនេះ? ចំនួនច្រើនគឺល្អប្រពៃហើយ ។ ព្រះជាម្ចាស់មិនចង់ឲ្យមានចំនួនមនុស្សតែពីបីនាក់នោះទេ តែព្រះអង្គចង់ឲ្យ "មនុស្សទាំងអស់បានសង្គ្រោះ និង បានយល់នូវសេចក្តីពិត" ហើយនៅថ្ងៃមួយ "មានមនុស្សហ្វូងធំដ៏ច្រើនឥតគណនាដែលគ្មាននរណាអាចរាប់បាន" និងបានទទួលជឿនូវសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់[៩] ។ ប៉ុន្តែរហូតដល់ថ្ងៃដែលត្រូវញែកស្រូវចេញពីស្រងែ ការទុកចិត្តលើចំនួនមនុស្សច្រើននោះអាចបង្ហាញឲ្យឃើញថាគ្មានការគិតដោយប្រើប្រាជ្ញាឡើយ ។ សេចក្តីស្មោះស្ម័គ្រ នៅក្នុងកិច្ចការ និង ភាពសច្ចៈទៀងត្រង់នៅក្នុងដួងចិត្ត ពិតប្រាកដជានឹងរង្វាន់យ៉ាងច្បាស់ ប៉ុន្តែនៅក្នុងពេលជាមួយគ្នានេះដែរ គឺជារឿយៗ មានការពិបាកក្នុងការឲ្យមនុស្សយើងអាចប៉ាន់ស្មានបានឡើយ ។ តើមានលក្ខណៈវិនិច្ឆ័យ ដែលមើលឃើញមួយណាបញ្ជាក់ឲ្យដឹងពីការទទួលជោគជ័យនៅក្នុងព័ន្ធកិច្ច?

ខ្ញុំសូមផ្តល់នូវការណែនាំថា អ្នកទទួលជ័យជំនះ ស្តែងចេញឲ្យឃើញពីជោគជ័យនោះឯង ។ គឺមិនសំអាងលើការ ដែលយើងបានធ្វើដោយល្អត្រឹមត្រូវនោះឡើយ ។ យើងត្រូវខំធ្វើការយ៉ាងស្វិតស្វាញ ដើម្បីទំព័រជីវិតរបស់យើង ដែលត្រូវគេចាប់ផ្តើមសរសេរមកនោះ មានមនុស្សម្នាក់ទៀតបន្តសាច់រឿង ដែលយើងបានចាប់ផ្តើមនោះ ជាបន្តទៅទៀត ។ បើគ្មានអ្នកណាបន្តវេននូវអ្វី ដែលយើងបានចាប់ផ្តើមនោះទេកិច្ចការរបស់

---

[៧] ១ ធីម៉ូថេ ៣១-១៣; ទីតុស ១:៦-៩

[៨] ទំនុកតម្កើង ៥០:១៦

[៩] ១ ធីម៉ូថេ ២:៤; វិវរណៈ ៧:៩-១០

យើងអាចរលាយរលត់ទៅគ្មាននរណា នឹកនាដូចជាការងារសាងសង់ប្រាសាទអង្គរវត្ត កាលពីរាប់សតវត្សរ៍មកហើយនោះដែរ ។ អ្នកកោតខ្លាចព្រះ អ្នកទទួលបាននូវការអប់រំល្អ និង អ្នកទទួលបានជោគជ័យនៅក្នុងការងារនោះ ប្រហែលជាមិនអាចចាត់ទុកបានថាបង្គោល បង្ហាញទិសដៅតែមួយគត់ នៃការទទួលជោគជ័យពីការងារនោះឡើយ ឬ សូម្បីតែការនោះគឺជាការចាំបាច់ក៏ដោយ ។ ប៉ុន្តែគេអាចពិពណ៌នាអំពីអ្នកដែលរកឃើញនូវកេរ្តិ៍នៃជោគជ័យណាមួយបាន ។

## សារៈសំខាន់នៃអ្នកបន្តវេន

ព្រះគម្ពីរបានថែងយ៉ាងញឹកញាប់ ពីសារៈសំខាន់នៃអ្នកបន្តវេន ។ នៅពេលលោកម៉ូសេព្រមានប្រាប់ពីសេចក្តីស្លាប់របស់គាត់ ដែលជិតមកដល់នោះ គាត់បានអធិស្ឋាន "សូមឲ្យព្រះយេហូវ៉ា ជាព្រះជាម្ចាស់នៃវិញ្ញាណនៃមនុស្សទាំងអស់នោះ រើសតាំងមនុស្សម្នាក់ពីសហគមន៍នេះ . . . ប្រយោជន៍ដើម្បីឲ្យរាស្ត្ររបស់ព្រះយេហូវ៉ា នឹងមិនវង្វេង ដូចជាចៀមដែលគ្មានអ្នកគង្វាល ។ "[១០] ពេលនោះព្រះជាម្ចាស់រើសតាំង យ៉ូស្វេដែលជាមនុស្សជំនិតរបស់លោក ម៉ូសេ តាំងពីវ័យយុវជនរបស់គាត់[១១] ដើម្បីឲ្យបន្តវេនដឹកនាំតពីគាត់ ។ ដោយឥតមានការសង្ស័យឡើយ ដែលថារាស្ត្រអ៊ីស្រាអែល បានសម្រេចជោគជ័យនៅក្រោមការ ដឹកនាំដ៏រឹងប៉ឹង និង ឆ្លាសវៃនៃអ្នកដឹកនាំម្នាក់នេះ និង ជីវិតនៃការងារ របស់លោក ម៉ូសេ គឺមិនរលាយសាបសូន្យទៅនៅលើទីវាលនៃទឹកដីម៉ូអាប់ទៅទិសខាងកើតនៃទន្លេយ័រដាន់នោះឡើយ ។ តែផ្ទុយទៅវិញ យើងមិនបានឮអ្វីទាំងអស់ពីអ្នកផ្តល់ដំបូន្មានសម្រាប់អ្នកទទួលតំណែងបន្តតពីយ៉ូស្វេ ។ ហេតុនោះ

---

[១០] *ជនគណនា ២៧:១៦-១៧*

[១១] *និក្ខមនំ ២៤:១៣; ៣៣:១១; ជនគណនា ១១:២៨; យ៉ូស្វេ ១:១*

ធ្វើឲ្យយើងមានសេចក្ដីក្រៀមក្រំយ៉ាងខ្លាំង ប៉ុន្តែយើងមិនមានការភ្ញាក់ផ្អើលឡើយ ដើម្បីអានរឿងនោះ បន្ទាប់ពី យ៉ូស្វេ និង ជំនាន់របស់គាត់ស្លាប់បាត់ទៅ "មួយជំនាន់ថ្មីបានកើតឡើង ដែលមិនទាំងស្គាល់ព្រះយេហូវ៉ា ឬ មិនទាំងបានដឹងអ្វី ដែលព្រះអង្គបានធ្វើសម្រាប់សាសន៍អ៊ីស្រាអែលនោះឡើយ" ។[១២] ដោយសារតែមានផលវិបាកនេះឯង អ៊ីស្រាអែលបានធ្លាក់ក្នុងគ្រោះមហន្តរាយ កាលពីសម័យនៃពួកចៅហ្វាយ ។

លោកបូជាចារ្យ អេលី គឺជាមនុស្សសុចរិត ប៉ុន្តែពួកកូនប្រុសរបស់គាត់ "គឺជាពួកមនុស្សទុច្ចរិត" ដែលគ្មាន "ការកោតខ្លាចចំពោះព្រះយេហូវ៉ាឡើយ ។ " ដោយព្រោះហេតុនោះហើយ ទើបពូជរបស់អេលីត្រូវស្លាប់ផុតពូជ ។ ដូចគ្នានេះដែរ សាំយ៉ូអែលស្មោះត្រង់ចំពោះព្រះអម្ចាស់ ប៉ុន្តែឯពួកកូនប្រុសគាត់វិញមិនស្មោះត្រង់សោះ គឺស៊ីសំណូក និង បំភ្លៃសេចក្ដីយុត្តិធម៌ ។ ដូច្នេះពូជរបស់សាំយ៉ូអែល និង តួនាទីទទួលខុសត្រូវរបស់ខ្សែស្រឡាយរបស់សាំយ៉ូអែល លែងបានបំរើការទៀតបែរជាក្រុមខ្សែស្រឡាយរបស់សូល និងក្រុមអ្នកគ្រប់គ្រងនៃអាណាចក្រ[១៤] ។ ហេសេគាដែលជាអ្នកសំណព្វរបស់ព្រះជាម្ចាស់ គឺមានអ្នកសោយរាជ្យបន្តម៉ាណាសេ ដែលមិនកោតខ្លាចព្រះ និង ការចម្រើនឡើងរបស់អាណាចក្ររបស់យូដានោះ ត្រូវបាក់ស្រុតដោយសារបុត្រារបស់ស្ដេចហេសេគានោះឯង ។[១៥] បើយើងចង់ឲ្យការទទួលជោគជ័យនោះស្ថិតស្ថេរនៅបាននោះ យើងត្រូវប្រុងប្រៀបហ្វឹកហ្វឺនអ្នកបន្តវេនដឹកនាំ បន្ទាប់ពីយើងឲ្យបានល្អ ។

---

[១២] *ពួកចៅហ្វាយ ២:១០*

[១៤] *១ សាំយ៉ូអែល ៤:១២,២៧-៣៦; ១ពង្សាវតាក្សត្រ ២:២៧*

[១៥] *២ ពង្សាវតាក្សត្រ ១៨:១-២១:១៨*

ព្រះយេស៊ូជ្រាបពីការនោះ ទើបហេតុដូច្នេះហើយ បានជានៅគ្រាពេលដែលវេលាកាន់តែកន្លងទៅមុខ ព្រះអង្គផ្តោតព្រះហឫទ័យទុកដាក់កាន់តែខ្លាំង ឡើងចំពោះព័ន្ធកិច្ចរបស់ព្រះអង្គ លើចំនួនមនុស្សតិចដែលប្តូរផ្តាច់ព្រមធ្វើការងាររបស់ព្រះអង្គ ប្រសើរជាជាងមនុស្សច្រើន ដែលងាយនឹងជឿ និង ងាយនឹងរសាយចិត្តនោះ ។ គ្មានបញ្ហាអ្វីឡើយ ចំពោះព្រះយេស៊ូក្នុងការទាក់ទាញឲ្យមានហ្វូងមនុស្សច្រើននោះ ដែលជួនកាលគេមកស្តាប់ព្រះអង្គនៅវាលរហោស្ថាន ដោយសារតែបានអាហារទទួលទានតែប៉ុណ្ណោះ ។ ប៉ុន្តែនៅពេល ដែលព័ន្ធកិច្ចរបស់ព្រះអង្គកាន់តែឈានដល់កំរិតកំពូលនៃការសុគត នៅឯកាល់វ៉ារីនោះ ព្រះយេស៊ូចំណាយពេលតិច ក្នុងការព្រោះពូជនៅតាមផ្លូវ និង ផ្តោតសំខាន់លើការសំលៀងកណ្តៀវរបស់ពួកអ្នកប្រមូលផលរបស់ព្រះអង្គវិញ ។ ព្រះអង្គសព្វព្រះហឫទ័យឲ្យការងាររបស់ព្រះអង្គស្ថិតស្ថេរជាប់នៅ ។ ព្រះអង្គផ្ទាល់អាចទាក់ទាញឲ្យមានហ្វូងមនុស្សមកច្រើនកុះករ និង ប្រហែលមានតែព្រះអង្គមួយគត់ដែលអាចនាំមនុស្សឲ្យ ជឿលើព្រះអង្គតាមរបៀបដូច្នោះ ។ ព្រះអង្គអាចធ្វើឲ្យគេបានឮដំណឹង ល្អយ៉ាងសុះសាយ នៅពេលនោះបានត្រាន់តែបានឮសើៗ តែមិនបានស្ថិតស្ថេរនៅឡើយ ពេលព្រះអង្គយាងទៅស្ថានសួគ៌វិញនោះ អ្វីៗក៏ចប់គ្មាននៅសល់ឡើយ ។ ដោយសារការដែលព្រះអង្គផ្តោតព្រះហឫទ័យទុកដាក់យ៉ាងខ្លាំង លើសិស្សរបស់ព្រះអង្គនោះ ព្រះអង្គជ្រាបយ៉ាង ច្បាស់ថាព្រះបន្ទូលរបស់ព្រះអង្គនឹងបានឮដល់យើងនៅឯភ្នំពេញ ដែលមានចម្ងាយ ៧៥០០ គីឡូម៉ែត្រ ពីទីក្រុងយេរូសាឡឹម និង ត្រូវចំណាយពេល ២ សហស្សវត្សរ៍ក្រោយទៀត ។

ព្រះរាជបំណងរបស់ព្រះអង្គ ចំពោះការនៅមានផលផ្លែស្ថិតស្ថេរជាប់នៅ គឺយើងបានឃើញនៅក្នុងសេចក្តីអធិប្បាយរបស់ព្រះយេស៊ូ.នៅក្នុងបន្ទប់ជាន់លើនៃកន្លែង ដែលពួកសិស្សស្នាក់នៅ ។ ព្រះអង្គមានបន្ទូលទៅកាន់សិស្សទាំង ១១ នាក់ "អ្នករាល់គ្នាមិនបានរើសខ្ញុំទេ តែគឺខ្ញុំ

បានជ្រើសអ្នករាល់គ្នា និង តែងតាំងអ្នករាល់គ្នាឲ្យចេញទៅ និង បង្កើតផលផ្លែ គឺជាផលផ្លែ ដែលនៅស្ថិតស្ថេរជាប់នៅ"[១៦] ។មធ្យោបាយមួយដែលអាចធានាថា ផលផ្លែរបស់យើងអាចស្ថិតស្ថេរជាប់នៅបាននោះ គឺត្រូវបំពេញមហាបេសកកម្ម ដែលព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យចេញទៅបង្កើតសិស្ស (គឺមិនគ្រាន់តែធ្វើឲ្យគេជឿនោះឡើយ) និង បង្រៀនឲ្យគេកាន់តាមព្រះរាជបញ្ញត្តិទាំងអស់របស់ព្រះគ្រីស្ទ ។ និយាយឲ្យស្រួលស្តាប់ទៅ គឺយើងត្រូវប្រុងប្រៀបបង្វឹកបង្វឹនដល់អ្នកបន្តវេនដឹកនាំបន្ទាប់ពីយើង ។ នៅក្នុងចំណោមព្រះរាជបញ្ញត្តិរបស់ព្រះយេស៊ូនោះគឺ យើងត្រូវហ្វឹកហ្វឺនសិស្សរបស់យើង ឲ្យចេះបង្ហាត់បង្រៀន និង បង្កើតសិស្សចំពោះមនុស្សដទៃ។ កិច្ចការរបស់យើងគឺមិនបានសម្រេចឡើយបើយើងគ្រាន់តែសិក្សា អធិប្បាយ បង្រៀន និង បំរើព្រះអង្គតែប៉ុណ្ណោះ ។ យើងត្រូវខិតខំសម្រួចជំនាញរបស់យើង និង ហ្វឹកហ្វឺនអ្នកដទៃ ដើម្បីឲ្យគេអាចរៀន អធិប្បាយព្រះបន្ទូល និង បំរើព្រះយ៉ាងមានប្រសិទ្ធិភាព ។ លើសពីនេះទៅទៀតនោះ សិស្សរបស់យើងមិនបានពេញលក្ខណៈដូចយើងទេ បើគេមិនបានទទួលការនូវហ្វឹកហ្វឺន ក្នុងនាមជាអ្នកបន្តវេនដឹកនាំពីយើង ។

និមិត្តដែលមានជាច្រើនជំនាន់មកហើយនេះ គឺបានចែងនៅក្នុងគម្ពីរ ២ ធីម៉ូថេ ២:២ ត្រង់កន្លែងដែលលោក ប៉ូល ជំរុញលើកទឹកចិត្តដល់អ្នកជំនិតរបស់គាត់ ឲ្យផ្ទេរនូវព្រះបន្ទូលដែលគេបានពីលោក ប៉ូល ឲ្យទៅមនុស្សស្មោះត្រង់ ដែលគេអាចបង្រៀនដល់អ្នកដទៃទៀត ។ ខគម្ពីរដ៏ខ្លីនេះនិយាយពីអ្នកដឹកនាំ ៤ "ជំនាន់" គឺលោក ប៉ូល ធីម៉ូថេ មនុស្សស្មោះត្រង់នឹងមនុស្សដទៃទៀត ។ ការធ្វើឲ្យមានផលផ្លែនោះស្ថិតស្ថេរបានគឺតម្រូវឲ្យមានសកម្មភាពដ៏យូរអង្វែង ។

---

[១៦] *យ៉ូហាន ១៥:១៦*

# ហេតុអ្វីបានជាមនុស្សយើងមិនបានហ្វឹកហ្វឺនអ្នកបន្តវេនពីយើងនោះ

ហេតុអ្វីបានជាជួនកាល យើងធ្វេសប្រហែសចំពោះការដ៏ចាំបាច់ដែលជាសមាសភាគ(គ្រឿងផ្សំ)សំខាន់បំផុត នៅក្នុងព័ន្ធកិច្ចដូច្នេះ? ហេតុផលមិនដូចគ្នាទេ ពីម្នាក់ទៅម្នាក់ទៀត ពីក្រុមទៅក្រុមមួយទៀត ប៉ុន្តែជារឿយៗការងារនេះគិតបញ្ចូលទាំងការលាយគ្នានៃចំណុចទាំងនេះគឺ:

១) ការបណ្តាក់ទុនចូលក្នុងអ្នកបន្តវេន តម្រូវឲ្យមានការបន្ទាបខ្លួន ។ គឺតម្រូវឲ្យមានឆន្ទៈ មិនចង់ក្លាយជាល្បីល្បាញហួសហេតុពេក ។ ដើម្បីឲ្យមានការរីកចំរើនឡើង ខ្ញុំខំប្រឹងប្រើកម្លាំងកាយចិត្ត ដើម្បីជួយស្អាងចិត្តដល់អស់អ្នកទាំងឡាយដែលនឹងទទួលការងារបន្តពីខ្ញុំ ខ្ញុំនឹងមិនចំណាយពេលច្រើនពេកនៅក្នុងការងាររបស់ខ្ញុំផ្ទាល់ប៉ុន្មានទេ ។ តែទោះជាយ៉ាងណាក៏ដោយ ការព្រមទទួលការអញ្ជើញមួយផ្សេងទៀតឲ្យធ្វើដំណើរទៅអធិប្បាយ ឬ សរសេរអត្ថបទ អាចផ្តល់ឲ្យខ្ញុំនូវជំរើសមួយគួរឲ្យចាប់អារម្មណ៍ ឬ ក៏អាចរក្សាឈ្មោះរបស់ខ្ញុំឲ្យមានជាប់នូវចំពោះមុខសាធារណជន ។ ប៉ុន្តែបើគិតពីភាពស្ថិតស្ថេរដ៏យូរអង្វែងវិញនោះ ការខំបង្ហាត់បង្រៀនសិស្សមួយក្រុមតូចដោយអត់ធ្មត់ និង ដោយសម្ងាត់គឺអាចបង្ហាញថាមានផលផ្លែច្រើនសម្រាប់នគរព្រះ ។ តើខ្ញុំព្រមបោះជំហានចេញពីកន្លែង ដែលមានមនុស្សចាប់អារម្មណ៍ច្រើននោះ ដើម្បីឲ្យអ្នកដទៃអាចរួមចំណែកជាមួយខ្ញុំ . . . ឬក៏ថ្ងៃណាមួយ អ្នកនោះអាចកាន់ការងារនេះជំនួសខ្ញុំ? ក្រុមជំនុំត្រូវការច្រើនថែមទៀត ដែលមានលក្ខណៈដូចជាលោក ប៉ុល ដែលរីករាយក្នុងការកាត់បន្ថយនៃការធ្វើដំណើរ និង ព័ន្ធកិច្ចរបស់គាត់ បើការនេះផ្តល់ឲ្យអ្នកដទៃនូវឱកាសប្រកាសដំណឹង

ពីព្រះគ្រីស្ទកាន់តែមានភាពអង់អាចមោះមុតនោះ ។[១៧] គឺត្រូវការឲ្យដូចជាព្រះយេស៊ូ ដែលបានមានបន្ទូលទៅកាន់ពួកសិស្សទាំង ១១ នាក់ "គឺជាប្រយោជន៍ល្អសម្រាប់អ្នករាល់គ្នា ដែលខ្ញុំត្រូវតែបែកពីអ្នករាល់គ្នា។"[១៨] តាមពិតទៅព្រះអង្គ ដែលត្រូវគេឆ្កាងនោះអាចធ្វើឲ្យពួកឃាតករ ដែលបានធ្វើគុតព្រះអង្គចាប់អារម្មណ៍យ៉ាងខ្លាំង ពេលដែលព្រះអង្គបានជួបផ្ទាល់ជាមួយនឹងគេ នៅពេលបន្ទាប់ពីព្រះអង្គរស់ពីសុគតឡើងវិញ ។ ប៉ុន្តែព្រះអង្គចង់ឲ្យព័ន្ធកិច្ចរបស់ពួកសាវ័ក បានទទួលជោគជ័យនោះព្រះអង្គចាំបាច់ត្រូវយាងទៅឋានសួគ៌វិញ ។

២) គឺតម្រូវឲ្យមានការអត់ធ្មត់ ។ និយាយដោយស្មោះត្រង់ទៅ យើងតែងតែចង់ធ្វើការងារអ្វីមួយ ដោយខ្លួនយើងផ្ទាល់ ព្រោះយើងយល់ថា វាងាយស្រួលជាង ។ យើងដឹងពីការប្ដេជ្ញាចិត្តរបស់យើង ចំពោះការល្អប្រសើរ ។ យើងដឹងពិតប្រាកដថា យើងនឹងធ្វើកិច្ចការបានសម្រេច ។ យើងមានទំនុកចិត្តលើបទពិសោធន៍ និង លើឯកទេសរបស់យើងផ្ទាល់ ។ ប៉ុន្តែដើម្បីបន្ទុកបណ្ដាក់ការទទួលខុសត្រូវចំពោះការងារដ៏សំខាន់ឲ្យទៅនរណាម្នាក់ទៀត ដែលមានសមត្ថភាពក្នុងការប្ដូរផ្ដាច់ក្នុងការងារមិនសូវពូកែដូចយើង . . . ចំពោះការធ្វើបែបនោះ គឺជាផ្នែកមួយដែលធ្វើឲ្យអ្នកដទៃអាចលួចលាស់ក្នុងដំណើរការងារនោះ . . . ការធ្វើបែបនោះទៅកើត គឺតម្រូវឲ្យមានការអត់ធ្មត់ ។ អ្នកនោះប្រហែលជាធ្វើឲ្យយើងអស់ទឹកចិត្ត ។ អ្វីដែលយើងគិតថាងាយស្រួល បែរជាអ្នកនោះចំណាយពេលយូរក្នុងការធ្វើការនោះ ។ យើងត្រូវស្អប់ចិត្តចំពោះផលិតផល ដែលមិនសូវល្អ . . . ឬក៏គ្មានឃើញផលិតផលអ្វីឡើយ ។ យើងអាចខឹង ហើយរបូតមាត់និយាយថា "អូ៎ មនុស្សមិនព្រមជឿ និងប្រព្រឹត្តការអាក្រក់ជំនាន់នេះអើយតើឲ្យខ្ញុំនៅជាមួយអ្នកដល់យូរប៉ុណ្ណាទៀតទៅ?

---

[១៧] ១៧ កិច្ចការ ១:១២-១៨

[១៨] ១៨ យ៉ូហាន ១៦:៧

តើឲ្យខ្ញុំត្រូវទ្រាំទ្រជាមួយអ្នកដល់កាលណាទៀត? ចូរនាំក្មេងប្រុសមកឲ្យខ្ញុំ ។”[១៩] តាមពិតទៅ យើងល្អឥតខ្ចោះមែន ចេតនារម្មណ៍របស់យើង គឺឥតកន្លែងចាប់កំហុសបានមែន និង ការគិតរបស់យើងគឺគ្មានកន្លែងបន្ទោសបានមែន ។ ប៉ុន្តែការទាំងនេះមិនទាន់ពិតនៅឡើយចំពោះអស់អ្នកដែលយើងផ្តល់នូវការហ្វឹកហ្វឺន ដូច្នេះចំពោះភាពល្អប្រសើរ ផ្នែកព័ន្ធកិច្ចរបស់យើងនោះ យើងត្រូវតែបន្ថែមសីលធម៌នៃការអត់ធ្មត់ បើសិនជាយើង ត្រូវបំប៉នសមត្ថភាពដល់អ្នកបន្តវេនបន្ទាប់ពីយើង ។

៣) គឺតម្រូវឲ្យមានពេល និង មានប្រាក់កាស ។ ការហ្វឹកហ្វឺនដល់អ្នកបន្តវេនបន្ទាប់ពីយើង តម្រូវឲ្យមានពេលវេលាដ៏យូរហូតទៅដល់រាប់ខែ (ឬរាប់ឆ្នាំទៀតផង) ។ គឺអាចតម្រូវឲ្យមានសំបុត្រយន្តហោះទីពីរ នៅពេលដែលគេមានគ្រប់គ្រាន់ កុំព្យូទ័រទីពីរទៀត ដើម្បីបញ្ចេញគំនិតដែលបានគិតទុកនោះ គឺជាអត្ថបទជាមូលដ្ឋានមួយបែបទៀត ។ ជាជាងការដែលពង្រីកនូវធនធាន និង ការទទួលស្គាល់នូវចន្លោះរវាងអ្នក “មាន” និង អ្នក “មិនមាន” ខាងផ្នែកវិញ្ញាណ ការប្តូរផ្តាច់ដើម្បីពង្រឹងអ្នកបន្តវេនឲ្យមានវ័យរឹងមាំនោះ និង ចំណាយពេលដើម្បីលើកកិរិតនៃការដឹកនាំនៃមនុស្សក្រោយ ។ ជំនឿគ្រីស្ទបរិស័ទគឺផ្ទុយពីទំនៀមទម្លាប់នៅពេលបច្ចុប្បន្ននេះ គឺមិនមែនគួរឲ្យស្រឡាញ់តែ “តួអង្គ” ដែលគិតតែពីផ្នែកព្រលឹងវិញ្ញាណ និង ភាពចំរុងចំរើននោះប៉ុណ្ណោះទេ ។ ប៉ុន្តែជំនឿគ្រីស្ទបរិស័ទ គឺប្រមូលផ្តុំជារូបកាយមួយដែល “យើងទាំងអស់គ្នាបានរួបរួមគ្នាដោយជំនឿ និង ការស្គាល់ចំពោះព្រះរាជបុត្រារបស់ព្រះជាម្ចាស់ និង មានជំនឿរឹងមាំ” ដែលជា “សរសៃពួរតាំទ្រសន្លាក់ឆ្អឹង” មាន

---

*(១៩) ម៉ាថាយ ១៧:១៧ ចំពោះការយកចិត្តទុកដាក់លើសំណួរនោះថា តើ ១ គម្ពីរនេះនិយាយសំដៅដល់នរណា អ្នកបកស្រាយព្រះគម្ពីរ បានកត់សំគាល់ឲ្យដឹងថា គឺសំដៅលើ “ការគ្មានជំនឿរបស់ពួកសិស្ស គឺជាចំណុចសំខាន់ ចំពោះការស្តីបន្ទោសរបស់ព្រះយេស៊ូ” ។*

ឥទ្ធិពល និង មានការរីកចំរើនលូតលាស់ "ដោយផ្នែកនីមួយៗ ធ្វើការងាររបស់ខ្លួន ។"[២០] ការមានទស្សនៈបែបនេះ គឺជួយសំអិតសំអាងមនុស្សមួយក្រុម ជាជាងការផ្ចង់ទៅលើ ជំរើសជើងឯកតែពីរបីនាក់នោះ និងតម្រូវឲ្យយើងផ្តោតយកចិត្តទុកដាក់ និង បណ្តាក់ទុនជាប្រាក់កាសទៅលើមនុស្សមួយក្រុម វិសេសជាងទៅលើមនុស្សខ្លាំងតែពីរបីនាក់ ។

៨) គឺតម្រូវឲ្យមានឆន្ទៈ ដើម្បីលះបង់តួលេខក្នុងស្ថិតិមួយរយៈពេលខ្លី ដោយព្រោះគិតសារៈសំខាន់ដែលមានរយៈពេលយូរ ។ នៅក្នុងការងាររបស់គ្រីស្តបរិស័ទទាំងអស់មានសម្ពាធមួយ គឺតម្រូវមានការពង្រីកការងារ ។ គេចង់បានចំនួនមនុស្សច្រើន គេចង់បានចំនួនស្ថិតិ គេចង់បានរឿងរ៉ាវសម្រាប់ចុះផ្សាយ ដែលមានភាពសោកនាដកម្មរំភើបចិត្តផ្លាស់ប្រែជីវិត និងចង់បានឲ្យគំរោងកម្មវិធីនានាមានដំណើរការទៅមុខ ។ ការនេះគឺជាការពិត ជាពិសេស នៅក្នុងបេសកកម្ម និង ការងាររបស់អង្គការក្រៅរដ្ឋាភិបាល ដែលទន្លេនៃរបាយការណ៍ត្រូវហូររហូតជាបន្តទៅដល់អ្នកផ្តល់ជំនួយ ដែលចង់ដឹងរឿងរ៉ាវដ៏លំអិតហួសហេតុ អ្នកផ្តល់ជំនួយនោះឯងអាចនឹងលែងមានការចាប់អារម្មណ៍ និង ដាក់ទុននៅកន្លែងណា ដែលលទ្ធផលនៃការធ្វើរបាយការណ៍នោះមិនមកដល់ភ្លាម និងមិនបានមករហូតទេនោះ ។ ការស្វែងរកចង់បានបរិមាណនោះ វាមិនខុសឆ្គងអ្វីឡើយ ។ គឺមានន័យថា យើងត្រូវតែបង្កើតការអ្វីមួយឲ្យវាកើតឡើង ។ ហើយការអ្វីមួយនោះ គួរតែបង្ហាញពីផលផ្លែ គឺមិនមែនមានតែស្លឹកនោះឡើយ ។ ប៉ុន្តែគឺអាចកើតឡើងបានដែរ ដែលថាសកម្មភាពដ៏មមាញឹកខ្លាំង និង ចំណាយលុយកាក់យ៉ាងច្រើន តែទោះជាយ៉ាងណាក៏ដោយយុទ្ធនាការ ឬសន្និសីទ ដ៏ធំធេងមិនប្រាកដថាមានផលផ្លែយ៉ាងធំសំខាន់ណាស់ណានៅថ្ងៃខាងមុខនោះ គឺមានផលផ្លែដូចគ្នា និង ចំពេល

---

[២០] *អេភេសូ ៤:១៣-១៧*

វេលា និង ប្រាក់កាស ដែលបានចំណាយដោយអត់ផ្ទុត់ តែមានការងារបង្កើតសិស្ស ដែលមិនមើលមិនសូវឃើញនៃការងារ TEE ឬក៏ព័ន្ធកិច្ចក្រុមតូចៗដទៃទៀត ។ការនេះមិនមែនជាបញ្ហាដេញដោលដល់តម្លៃនៃអ្នកជំនាន់មុននោះទេ ប៉ុន្តែគឺជំរុញឲ្យយើងនៅស្មោះស្ម័គ្រចំពោះអ្នកជំនាន់ក្រោយ បើការងារនោះគឺជាអ្វីមួយនៅបច្ចុប្បន្ននេះត្រូវការសំណើដូច្នេះ ។ យើងត្រូវតែធ្វើដូច្នោះ ទោះបីជាក្នុងមួយរយៈនេះ មានរបាយការណ៍ដ៏តិចតួចក៏ដោយ ។ ពួកអ្នកផ្តល់ ជំនួយត្រូវតែព្រមទទួលនូវការពិតនេះ ។

៥) អ្នកបន្តវេន រំលឹកអ្នកដឹកនាំអំពីភាពលាចាកលោករបស់ខ្លួន ។ ប្រហែលជាដោយមិនបានជាគិតឲ្យដិតដល់ ទើបមិនបានត្រៀមដើម្បីហ្វឹកហ្វឺនដល់អ្នកបន្តវេន គឺថាការធ្វើបែបនោះគឺជា ការរំលឹកឲ្យដឹងច្បាស់ពីការជំនួសពីតំណែង ដែលអាចធ្វើបាន និង នៅពេលដែលអ្នកដឹកនាំនោះអស់ជីវិតទៅ ។ បើសិនជាយើងរស់នៅអស់កល្បជានិច្ច ឬ ស្នាក់នៅក្នុងកន្លែងមួយរហូតនោះ មិនចាំបាច់អ្វីឲ្យមានការផ្លាស់ប្តូរតំណែងឡើយ ។ ការស្នាក់ស្ទើរ ឬ ការបដិសេធន៍មិនព្រមប្រុងប្រៀបឲ្យអ្នកណាម្នាក់ឲ្យបន្តវេននៅក្នុងព័ន្ធកិច្ចរបស់ខ្ញុំពីដំបូងទីនោះ ប្រហែលជាយុទ្ធសាស្ត្រមួយដែលមិនសូវដឹងខ្លួនច្បាស់លាស់ ដើម្បីគ្របបាំងការលាចាកពីលោកនេះទៅរបស់ខ្ញុំ ។

## គំរូនៃការហ្វឹកហ្វឺនរបស់ព្រះយេស៊ូ

ព្រះយេស៊ូធ្វើតាមដំណាក់ការ ៤ យ៉ាង ក្នុងការហ្វឹកហ្វឺនដល់ពួកអ្នកដែលទទួលការងារបន្ទាប់ពីព្រះអង្គៈ

១) ការជ្រើសរើសៈ ពួកសាវ័កមិនមែនជាក្រុមអ្នកស្ម័គ្រចិត្ត ព្រមមកដោយចិត្តឯងនោះឡើយ ។ បន្ទាប់ពីចំណាយពេល ដោយអធិស្ឋានមួយយប់ ព្រះយេស៊ូបានជ្រើសរើសសិស្សបាន ១២ នាក់ ដែលព្រះអង្គ

ចង់បាន[២១] (ក្នុងចំណោមសិស្ស ដែលព្រះអង្គមានជាច្រើននោះ) ។ ព្រះរាជសកម្មភាពរបស់ព្រះអង្គ ខុសពីគំរូនៅក្នុងបច្ចុប្បន្ននេះ ដែលទទូចសុំឲ្យមានអ្នកស្ម័គ្រចិត្ត ឬ ព្រមទទួលជាសិស្សតាមក្រមសីលធម៌ដល់មនុស្សទាំងអស់ ដែលអាចបង់ថ្លៃដល់ការបង្រៀននោះ ។ ការទទូចសុំឲ្យមានអ្នកស្ម័គ្រចិត្ត នាំឲ្យមានគ្រោះថ្នាក់ពីរយ៉ាងដល់ការជំរុញលើកទឹកចិត្តដល់អ្នកទាំងឡាយណា ដែលគ្មានការងារនៅក្នុងផ្នែកដឹកនាំសោះ ឲ្យមកសុំធ្វើជាសិស្ស និង មានមួយចំណែកខ្លះទៀតនៃហេតុផលបែបហ្នឹងបណ្តាលឲ្យ អ្នកដែលពូកែ និង អ្នកមានគុណសម្បត្តិដកខ្លួនចេញ ។ លោក ប៉ូល ធ្វើតាមគំរូរបស់ព្រះយេស៊ូ ក្នុងការជ្រើសរើសដល់អ្នកទទួលការងារបន្ទាប់ពីគាត់គឺថា "បងប្អូននៅឯក្រុង លីស្ត្រា និង អ៊ីកូនាមនិយាយសរសើរដល់ ធីម៉ូថេ ។ លោក ប៉ូលចង់នាំគាត់ឲ្យទៅធ្វើដំណើរជាមួយ . . ." ដោយហេតុនោះហើយ ការជ្រើសរើសបានត្រឹមត្រូវ និង ហ្មឹកហ្មឺនបានច្បាស់នោះ លោកប៉ូលបានក្លាយជាមនុស្ស ដែលគ្មានអ្នកណាអាចប្រៀបផ្ទឹមបានឡើយ[២២] ។ គំរូជាទូទៅនៅក្នុងព្រះគម្ពីរសញ្ញាថ្មីគឺការជ្រើសរើសអ្នកដែលមានសក្តានុពល ដោយសារអ្នកដឹកនាំ ដែលស្ថាបនិកនោះ[២៣] ។ ទាំងរបៀបស្ម័គ្រចិត្ត និង ទាំងរបៀបបោះឆ្នោតរើសដោយក្រុមជំនុំទាំងមូល (ដែលជាទូទៅនឹងទទួលបានមនុស្ស ដែលមានការយល់ដឹង និង ភាពពេញវ័យនៃជំនឿគ្រីស្ទបរិស័ទគ្រប់ស្រទាប់ទាំងអស់) គឺមិនសូវឃើញមានទេ ។[២៤]

---

[២១] *លូកា ៦:១៧; ម៉ាកុស ៣:១៣*

[២២] *កិច្ចការ ១៦:២-៣; ភីលីព ២:១៩-២២*

[២៣] *ឧទាហរណ៍ កិច្ចការ ១៤:២៣; ១៥:២២; ទីតុស ១:៥*

[២៤] *កិច្ចការ ៦:៣-៤ ប្រហែលជាករណីលើកលែង ។ ប៉ុន្តែក្រុមជំនុំនៅក្មេងខ្ចីនៅឡើយត្រង់ចំណុចនេះ ហើយតាមរយៈការល្បងល និង ការ បៀតបៀនផ្សេងៗ និង មានគំនិតស៊ីជម្រៅលើផ្នែកវិញ្ញាណជាងការពិតចំនួនមធ្យមភាគ នៅក្នុងប្រវត្តិនៃក្រុមជំនុំភាគច្រើន (សូមមើលឧទាហរណ៍នៅក្នុង កិច្ចការ ៥:១៣) ។*

បើសិនក្រុមជំនុំសព្វថ្ងៃនេះ ដើរតាមគំរូរបស់ព្រះយេស៊ូនោះ គឺដំបូងយើងត្រូវមានបំណង ចង់បានអ្នកបន្តដោយហ្វឹកហ្វឺនគេ និង អធិស្ឋានសូមឲ្យព្រះជាម្ចាស់បង្ហាញយើងឲ្យមើលឃើញមនុស្សទាំងនេះ។ យើងអាចប៉ាន់ប្រមាណមើលបេក្ខជន ដោយសារពន្លឺនៃការបង្ហាញឲ្យឃើញពីគុណសម្បត្តិ[២៥] ។ នៅពេលដែលយើងធ្វើការស្ទង់ប៉ាន់មើល និង អធិស្ឋានព្រះជាម្ចាស់អាចបើកសម្ដែងឲ្យយើងឃើញពីការ ដែលព្រះអង្គជ្រើសរើស[២៦] ។ បន្ទាប់មកយើងអាចទៅឯអ្នកនោះ ដើម្បីបញ្ជាក់ឲ្យច្បាស់ថាតើពួកគេព្រមស្ម័គ្រចិត្ត ទទួលនូវការហ្វឹកហ្វឺន និង បំរើព្រះឬក៏អត់ ។

២) ការសង្ខេបៈ សាច់រឿងរបស់លោកម៉ាកុស ស្ដីពីការជ្រើសតាំងពួកសាវ័កបានចែងថា ផែនការរបស់ព្រះយេស៊ូគឺថា "ពួកសាវ័កត្រូវនៅជាមួយព្រះយេស៊ូ" មុនពេលព្រះអង្គ "បញ្ជូនគេចេញទៅផ្សាយដំណឹង និង មុនពេលគេមានសិទ្ធិអំណាច ដើម្បីដេញអារក្ស" ។ ជំហានដំបូងរបស់ពួកសាវ័ក គឺត្រូវមើល និង ត្រូវស្ដាប់ ។ មុនដំបូងព្រះយេស៊ូធ្វើការទាំងអស់ ។ ព្រះយេស៊ូបង្រៀនប្រោសជម្ងឺ និង ដេញអារក្ស ។ ពួកសាវ័កគ្រាន់តែជួយអុំទូក ឬ ជួយចែកនំបុ័ង និង ត្រី ប៉ុន្តែការងារដំបូងរបស់គេនោះគឺត្រូវរៀន ។ គ្មានការបញ្ចេញឡើយ បើគ្មានការបញ្ចូលជាមុននោះទេ ។ គឺពិបាករកអ្នកដឹកនាំណាម្នាក់ ដែលល្អ ដោយពីមុនមិនធ្លាប់ជាអ្នកដើរតាមដ៏ល្អនោះ ។ មនុស្សណាម្នាក់ ដែលឆាប់នឹងនិយាយតែងតែគ្មានពាក្យនិយាយនៅពេលចុងក្រោយ ។ អ្នកដែលចង់លេចមុខលេចមាត់ហួសហេតុពេកនោះ អាចចាត់ទុកថា ជាមនុស្សមានចរិតលក្ខណៈ ដែលគិតថាមានតែខ្លួនឯងគ្រាន់បើជាងអ្នកដទៃ គឺមិនមែនមាន

---

(២៥) *ឧទាហរណ៍ ១ធីម៉ូថេ ២:១១-៣:១៣; ទីតុស ១:៥-៩*

(២៦) *គឺស្ថិតនៅបរិបទនៃការថ្វាយបង្គំ និង ការអធិស្ឋានតម ដែលក្រុមជំនុំ បានដឹងពីការត្រាស់ហៅរបស់ព្រះចំពោះ លោក បាណាបាស សូល (កិច្ចការ ១៣:១-៣)*

ចរិតលក្ខណៈជាបាវបំរើព្រះឡើយ ។ ជាការប្រសើរគួរតែរៀន និង នៅស្ងៀមស្ងាត់ជាមុនសិន ។ ដោយសារការមានសេរីភាព ដើម្បីមើល និង ស្តាប់ដោយមិនមានការបង្ខំឲ្យធ្វើការអ្វីនោះ បេក្ខជនផ្នែកដឹកនាំអាចទទួលព្រះរាជសារ វិធីសាស្ត្រ និង ស្មារតីផ្នែកដឹកនាំ ។ ជាការប្រសើរនោះ ត្រូវដឹងថាអ្នកកំពុងទៅឯណា មុននឹងសុំឲ្យគេដើរតាមនោះ ។ ដំណាក់ការដំបូងនៃការអភិវឌ្ឍន៍អ្នកដឹកនាំ គឺត្រូវដឹងប្រាកដថា យើងមានអ្នកដែលប្តូរផ្តាច់ ព្រមស្តាប់ និង មើលដោយស្មោះស្ម័គ្រ ។

៣) **ការហាត់ការៈ** ព្រះយេស៊ូមិនបានទុកឲ្យសិស្ស ដែលព្រះអង្គជ្រើសរើស នៅតែជាអ្នកសង្កេតមើលការងាររបស់ព្រះអង្គ ឬ ព្រះអង្គមិនបានរុញបង្ខំឲ្យគេធ្វើការពេញភ្លាមដែរ ។ ដំណឹងល្អគួរតែទៅឲ្យសិស្សទាំង ១២ នាក់ ដោយការផ្តល់កិរិតនៃការទទួលខុសត្រូវបន្តិចម្តងៗ ។ យោងតាមម៉ាថាយជំពូក ១០ ព្រះយេស៊ូបានបញ្ជូនពួកសិស្ស ១ គូៗ ដើម្បីទៅបំពេញព័ន្ធកិច្ច ដែលព្រះអង្គកំណត់ឲ្យ ។[២៦] ហេតុផលពិតដែលព្រះអង្គធ្វើបែបនោះគឺ ព្រះអង្គរំលឹកឲ្យគេនឹកចាំពីព្រះរាជព័ន្ធកិច្ចរបស់ព្រះអង្គផ្ទាល់ បង្ហាញថាដំណាក់ការដំបូងនៃ "ការដែលពួកគេនៅជាមួយព្រះអង្គ" គឺមិនបានផ្តល់ជាជំនួយអ្វី ដល់ដំណើរការហ្វឹកហ្វឺន ។ ពួកសិស្សត្រូវតែដូចជាគ្រូ និង ចៅហ្វាយរបស់គេ ។[២៧] នៅពេលចុងបញ្ចប់នៃការហាត់ការនេះ ពួកសិស្សបានរាយការណ៍មកព្រះយេស៊ូចំណាយពេលសញ្ជឹងគិត និង ជំរះសតិឡើងវិញ[២៨] និង បន្តការរៀនសូត្ររបស់គេ ។ ឥឡូវនេះគេចេះធ្វើការងារ ដោយសារបទពិសោធន៍ដែលគេបានពូពីព្រះយេស៊ូ គឺមិនគ្រាន់តែព្រះបន្ទូលប៉ុណ្ណោះទេ ប៉ុន្តែគឺជាសេចក្តីពិត និង អំណាចចេស្តា ។ គ្មានអ្វីដែលធ្វើឲ្យកើនបំណងចិត្ត និង

---

[២៦] *សូមមើលគម្ពីរស្របគ្នានៅក្នុង ម៉ាកុស ៦ និង លូកា ៩ ។*

[២៧] *ម៉ាថាយ ១០:២៤-២៥*

[២៨] *ម៉ាកុស ៦:៣០-៣១; លូកា ៩:១០*

សមត្ថភាពឡើយ ចំពោះអ្វីដែលយើងបានទទួលនោះ ដូចអ្វីដែលយើងបានរៀនរួចមកហើយនោះទេ ។ ដូចគ្នាដែរ និងការមើលឃើញពីព័ន្ធកិច្ចរបស់ពួកសិស្សទាំងដប់ពីរ ត្រូវការមើលឃើញ ឲ្យបានស៊ីជម្រៅថែមទៀត ។ ពួកសិស្សបានភ្លក្សនូវអំណារ និង អំណាចចេស្ដានៃអាណាចក្រព្រះ ឥឡូវនេះ ពួកសិស្សត្រូវយល់ និង ព្រមទទួលតម្លៃនៃការខំប្រឹងប្រែងនោះ ។[២៩]

បើសិនជាយើងប្រាថ្នា ចង់ដើរតាមគំរូរបស់ព្រះយេស៊ូ យើងត្រូវតែតម្រង់ទិសដៅ និង ពិនិត្យមើលពីការចំរើនលូតលាស់នៃការផ្ទេរការងាររវាងសកម្មភាពនៃការសង្កេតមើល និង សកម្មភាពការងារបែបឯករាជ្យ ។ ធ្វើដូច្នេះ យើងនឹងធ្វើតាម សេចក្ដីថ្លែងការណ៍ដែលបង្ហាញគំនិតរបស់លោក ប៉ូល ដែលថាបេក្ខជនដែលត្រូវរើសមកធ្វើជាចាស់ទុំជំនួយ "គឺត្រូវល្បងលជាមុនសិន" និង ត្រូវរកឲ្យឃើញគ្មានកន្លែងណាដែលអាចបន្ទោសបាន មុនពេលរើសមកឲ្យបំរើការងារ ។[៣០] អ្នកទទួលការងារបន្ទាប់ពីយើង ត្រូវតែមានបទពិសោធន៍ទាំងនៅក្នុងការអនុវត្តន៍ការងារផ្ទាល់ និង នៅក្នុងផ្នែកទ្រឹស្តីរបស់ព័ន្ធកិច្ចផងដែរ ។ ការអនុវត្តន៍នោះអាចចាប់ផ្ដើមឡើង ដោយមានការទទួលខុសត្រូវតូចៗ សូម្បីតែការងារ ដែលបន្ទាបខ្លួនដូចជា "ការចាក់ទឹកស្រោចដៃ" របស់អ្នកជាគំរូរបស់គេ ។[៣១] សេចក្ដីស្មោះត្រង់នៅក្នុងការងារតូចគឺ មានគុណប្រយោជន៍ចំពោះការទទួលខុសត្រូវយ៉ាងច្រើន ។[៣២] យើងត្រូវការផ្ដល់ឲ្យសិក្ខាកាមរបស់យើងនូវ "ការទទួលខុសត្រូវដ៏តិចតួច" ដូចជាការមើលថែរបស់របរផ្សេងៗ ឈរស្វាគមន៍ភ្ញៀវ ដែលចូលមកថ្វាយបង្គំនៅថ្ងៃអាទិត្យ

---

[២៩] ម៉ាកុស ៨:៣១-៣៥

[៣០] ១ ធីម៉ូថេ ៣:១១

[៣១] ២ ពង្សាវតាក្សត្រ ៣:១១

[៣២] ម៉ាថាយ ២៥:២១-២៣

ហើយពេលនោះបើឃើញថា គេស្មោះត្រង់នឹងការងារនោះហើយ ចូរផ្ដល់ការងារបន្ថែមទៀត ។ នៅក្នុងរបៀបនេះ បើស្ថាប័នហ្វឹកហ្វឺនព្រះគម្ពីរជាមិនបានពិចារណាក្នុងការផ្ដល់នូវ ការបំរើជាក់ស្ដែងណាមួយ ដើម្បីទុកជាផ្នែកមួយនៃការងាររបស់ខ្លួននោះទេ កម្មវិធីសិក្សានៃសាលានោះត្រូវតែបន្ថែមការអនុវត្តន៍ដ៏សំខាន់ របស់ក្រុមជំនុំក្នុងស្រុក មុនពេលសូម្បីតែនិស្សិតថ្នាក់ខ្ពស់អាចពិចារណាពីការរៀបចំខ្លួន ដើម្បីបំរើការនៅក្នុងព័ន្ធកិច្ច ។

៤) ការប្រគល់ភារកិច្ច និង ការបណ្ដោយឲ្យធ្វើ ។ ពួកសិស្សទាំង ១២ នាក់ មិនបានធ្វើការបានគាប់ប្រសើរឡើយ នៅក្នុងរយៈពេលនៃការរៀនសូត្ររបស់គេ និងក្នុងការត្រួតពិនិត្យមើលព័ន្ធកិច្ចដែលគេត្រូវបំរើ ។ សិស្សម្នាក់បានចូលដៃជាមួយសត្រូវ ។ នៅសល់ ១១ នាក់ មិនបានសម្រេចនូវ ការងារដ៏សំខាន់ ក្នុងការលុតជង្គង់អធិស្ឋាននៅក្នុងពេលម៉ោងដ៏សំខាន់ ហេតុដូច្នេះហើយទើបគេមិនអាចឈ្នះបាន ។ ប៉ុន្តែនៅក្នុងចម្លើយនៃ សេចក្ដីអធិស្ឋានរបស់ព្រះអម្ចាស់ ជំនឿមិនមែនបរាជ័យទាំងស្រុងនោះឡើយ[៣៣] ។ទីបំផុតនៃនោះក៏មកដល់គឺនៅពេលដែលពួកសិស្សបាន ទទួលការងារដ៏ពេញលេញមួយ រហូតដល់ទ្រង់ ទ្រាយធំ និង កាន់តែមានព័ន្ធកិច្ចពេញពេលច្រើនជាងនៅក្នុងម៉ាថាយ១០ គឺកិច្ចការម្ដងនេះ គឺសម្រាប់លោកិយទាំងមូល[៣៤] គឺបានន័យថា ព្រះអម្ចាស់បានទុកឲ្យពួកសិស្សធ្វើការងាររបស់ព្រះអង្គជាបន្ត"ដោយខ្លួនគេផ្ទាល់"ក្រោមការដឹកនាំ និង ផ្ដល់ព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ ស្រដៀងគ្នានេះដែរ សិស្សរបស់យើងផ្ទាល់ នឹងមានភាពកំសោយដោយឥតសង្ស័យ និង មិនបានសម្រេចតាមការងារអ្វី ដែលគេបានធ្វើ នៅពេលថ្ងៃនោះមកដល់ ដើម្បីឲ្យពួកគេទទួលការងារជំនួសយើង ។ ប៉ុន្តែដើម្បីទទួលការងារ

---

[៣៣] *លូកា ២២:៣០-៣១*

[៣៤] *ម៉ាថាយ ២៨:១៩; ម៉ាកុស ១៦:១៥*

បន្ទាប់នោះ គេត្រូវតែធ្វើតាមគំរូលោក ប៉ូល ដែលថាយើង "ប្រគល់គេទៅព្រះជាម្ចាស់និងប្រគល់ឲ្យគេនូវព្រះបន្ទូលនៃព្រះគុណរបស់ព្រះអង្គដែលអាចពង្រឹងឲ្យគេបានរឹងមាំឡើង និង អាចផ្តល់ឲ្យគេនូវមត៌ករបស់ព្រះជាម្ចាស់" ។[៣៥] ការងារយើងបានចប់សព្វគ្រប់ ឯការងាររបស់ពួកគេទើបតែចាប់ផ្តើម ។

## ការសិក្សាតាមករណីកើតឡើងនៅស្រុកខ្មែរ

គំរូដែលមានលក្ខណៈវិជ្ជមានមួយ ចំពោះការហ្វឹកហ្វឺនអ្នកបន្តវេន គឺបានធ្វើឡើង នៅក្នុងការងាររបស់ស្ថានការយុវជននៃប្រិយសម្ពន្ធគ្រីស្តបរិស័ទកម្ពុជាគឺមានក្នុងការធ្វើសន្និសីទ ប្រចាំឆ្នាំនៅទីក្រុង កំពង់សោម ។ ការកកើត និង ការរៀបចំផែនការភាគច្រើនដោយសារអ្នកមកពីក្រៅប្រទេស កាលពីឆ្នាំ ១៩៩៥ ពីមួយឆ្នាំទៅមួយឆ្នាំការងារ និង ការទទួលខុសត្រូវ គឺខ្មែរជាអ្នកចាត់ចែងកាន់តែច្រើនឡើងៗ ។ អ្នកខ្លះដែលបានចូលរួមក្នុងឆ្នាំ ១៩៩៦ ដែលចូលរួមក្នុងនាមជាអ្នកបោះជំរុំ តែឥឡូវជាអ្នកបំរើការងារ ក្នុងកម្មវិធីបោះជំរុំនោះទៅវិញ ។ ការបង់ថ្លៃចុះឈ្មោះរបស់អ្នកចូលរួម កើនឡើងជារៀងរាល់ឆ្នាំ ដើម្បីបង្កើនចំនួនទ្វេនៃអត្រានៃប្រាក់ចុះឈ្មោះកាលពីពេលដំបូង ។ ហេតុដូច្នេះហើយ តាមរយៈនៃប្រាក់បង់ថ្លៃចុះឈ្មោះចូលរួមរបស់អ្នក ដែលនៅក្នុងទីក្រុងភ្នំពេញ ឥឡូវនេះកើនឡើង រហូតអាចចេញថ្លៃជិតពាក់កណ្តាល នៃថ្លៃដែលបានចំណាយសម្រាប់អ្នកបោះជំរុំម្នាក់ៗ ។ ខ្លឹមសារនៃការបោះជំរុំឆ្នាំ ២០០១ ចម្រៀងបាវចនា ក្រុមសន្តិសុខ ក្រុមសង្គ្រោះបន្ទាន់ ក្រុមកីឡា និង ការទទួលខុសត្រូវផ្សេងៗដទៃទៀត ស្ទើរតែជាកិច្ចការ ដែលខ្មែរធ្វើទាំងស្រុងទៅហើយ ។ ពួកអ្នកដឹកនាំមកពីបរទេសនៅតែជួយកោះប្រជុំរៀបចំផែនការឲ្យបានទាន់ពេល ការរៃអង្គាសថវិកា ដោះស្រាយបញ្ហា រៀបចំ

---

[៣៥] កិច្ចការ ២០:៣២

ដាក់មេរៀន ដើម្បីសិក្សា និង ចាត់តាំងឲ្យមានអ្នកដឹកនាំ និង រៀបចំប្រព័ន្ធគណនេយ្យ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ការងារទាំងអស់នេះត្រូវដាក់ឲ្យអ្នកដឹកនាំថ្នាក់ជាតិ ដើម្បីពិនិត្យមើលដែរ ។ សន្និសីទនេះ គួរតែរៀបចំចាត់ចែង ដោយមិនចាំបាច់មានអ្នកមកពីបរទេសឡើយ ទោះបីជាពួកជនបរទេស នៅតែខំបង្ហាញពីប្រសិទ្ធិភាពរបស់ខ្លួន តាមរយៈការរួមចំណែក និង កម្លាំងកាយចិត្តរបស់គេក៏ដោយ ។

## សរុបសេចក្តី

សេចក្តីបង្រៀនរបស់ព្រះយេស៊ូ នៅក្នុងម៉ាថាយ គឺត្រូវបង្កើតសិស្ស បង្រៀនឲ្យគេកាន់កាប់តាមគ្រប់ទាំងសេចក្តីបង្គាប់របស់ព្រះអង្គ ។ ការស្តាប់បង្គាប់របស់យើង ចំពោះការងារនោះ គឺនៅតែមិនបានចប់សព្វគ្រប់ឡើយ បើសិនយើងមិនបានបង្រៀន យ៉ាងហោចណាស់ឲ្យបានម្នាក់នោះទេ គឺដោយពាក្យសម្តីរបស់យើង គំរូរបស់យើង និង ត្រួតពិនិត្យមើលពីការខំប្រឹងប្រែងរបស់អ្នកម្នាក់នោះ ក្នុងការអនុវត្តន៍ធ្វើការងារ និង ពង្រីកការងារបន្ទាប់ពីយើងចេញបាត់ទៅ ។

មានគ្រូគង្វាលជាច្រើន ដែលរវល់យ៉ាងខ្លាំង ពីការអធិប្បាយបង្រៀន ធ្វើដំណើរពីមួយកន្លែងទៅមួយកន្លែង ធ្វើជាប្រធាននៃគណៈកម្មាធិការផ្សេងៗ និង បំពេញការដ៏សំខាន់ផ្សេងៗ តែធ្វើការទាំងអស់នេះដោយខ្លួនឯងផ្ទាល់ ។ គ្រូគង្វាលទាំងនេះអាចគិតថា គឺជាមោទនភាពមែនទែន នៅពេលមានគេនិយាយថា "លោកគ្រូ គ្មាននរណាម្នាក់អាចធ្វើការបានល្អ ដូចលោកឡើយ!" នៅពេលដែលលោកគ្រូនោះស្លាប់ទៅ ឬផ្លាស់ទៅកន្លែងណាផ្សេង ក្រុមជំនុំ ឬ អង្គការ ដែលគាត់បានដឹកនាំ ជាញឹកញយតែងតែដាំក្បាលចុះលឿនស្លេវ ពីព្រោះដោយសារតែមានភាពហេងហាងផ្នែកដឹកនាំ និង បទជំនាញ ដែលលើកបន្តភ្លាមៗនោះ ។ អ្នកដទៃអាចនិយាយទាំងរបូតមាត់ចេញមកដោយមិនបានគិតថា "យី! គាត់នេះជា

អ្នកដឹកនាំក៏ពូកែមែនទែន គ្មាននរណាម្នាក់ពូកែដូចគាត់ឡើយ ។ ការងារទាំងឡាយនឹងដួល បើសិនជាគ្មានគាត់ទេនោះ" ។ ប៉ុន្តែ តើនេះជាសញ្ញាបង្ហាញពីការទទួលជោគជ័យ ឬ បរាជ័យ? តើមិនមែនជារង្វាស់សម្រាប់ការងារទទួលបានជោគជ័យរបស់យើង ថាតើអ្វីដែលយើងបានធ្វើនោះជួយឲ្យយើងរស់នៅបាន ថាតើអ្នកដទៃបានទទួលការហ្វឹកហ្វឺន ដើម្បីបន្តនិង ពង្រីកការងាររបស់យើង ឬក៏អត់នោះទេ? តើព័ន្ធកិច្ចសំដៅលើការទទួលបានជោគជ័យផ្ទាល់ខ្លួន ឬ ជោគជ័យរបស់ក្រុមជំនុំ?

សំណុំឯកសារ ២/៣ (កក្កដា ២០០១)៖ ៩៣-៩៩



# ជួបជាមួយ លោកគ្រូ សម សារិន

*លោកគ្រូ សម សារិន*

ខ្ញុំជាក្មេងកំព្រាឪពុកតាំងពីអាយុប្រហែល ៥ ឆ្នាំ ។ ដល់អាយុ១៥ ឆ្នាំ គឺឆ្នាំ ១៩៥៥ ខ្ញុំបានទៅរស់នៅជាក្មេងវត្តនៅក្រុងភ្នំពេញដើម្បីសិក្សា ។ ក្នុងកម្រិតទាបនៃការសិក្សារបស់ខ្ញុំ ដែលបានត្រឹមក្រោមឌីសប្លូមនោះ ពិបាករកការធ្វើចិញ្ចឹមជីវិតក៏លះចោលការសិក្សាក្នុងឆ្នាំ១៩៦៣ ទៅរស់នៅក្នុងជនបទខេត្តបាត់ដំបង ហើយបានរៀបការនៅឆ្នាំ១៩៦៥ ។ យើងបាននាំគ្នាទៅរស់នៅឯប៉ៃលិន រហូតដល់ស្រុកធ្លាក់ចូលរបបខ្មែរក្រហម ក៏ត្រូវគេជម្លៀសមកដល់ភ្នំប្រជាកជាទីដែលប្រពន្ធខ្ញុំនិងកូនបីនាក់ត្រូវស្លាប់អស់ក្នុងឆ្នាំ១៩៧៦ ។

នៅចុងឆ្នាំ១៩៧៩ ខ្ញុំបានចូលទៅនៅជំរំខៅអ៊ីដាង ប្រទេសថៃ គឺនៅទីនោះហើយដែលព្រះយេស៊ូបានបើកសម្តែងអង្គទ្រង់ឲ្យខ្ញុំស្គាល់ថា ទ្រង់ជាព្រះបង្កើតគ្រប់អ្វីទាំងអស់ ។ ខ្ញុំបានស្គាល់ព្រះនាមទ្រង់តាំងពីឆ្នាំ ១៩៥៥ តែនឹកស្មានថា ព្រះអង្គជាព្រះរបស់សាសនាឯទៀត ។ នៅក្នុងខែមករា ឆ្នាំ១៩៨០ ខ្ញុំចាប់ផ្តើមជីវិតថ្មីក្នុងព្រះគ្រីស្ទ ។ កាលទទួលពិធីជ្រមុជទឹករួចក្នុងខែមិនា ហើយត្រូវផ្លាស់ទៅនៅជំរំស្រះកែវទី២ ដើមឆ្នាំ១៩៨១

ខ្ញុំបានចូលរៀនក្នុងសាលាគម្ពីរបើកសម្រាប់រយៈពេលខ្លី ទាំងត្រូវបានក្រុមជំនុំរើសតាំងជាចាស់ទុំ ។ ក្រោយពីធ្វើសម្ភាសទៅកាន់សហរដ្ឋអាមេរិកធ្លាក់នៅជំរំកាំពុតក្នុងឆ្នាំ១៩៨២ នៅដើមឆ្នាំ១៩៨៣ ត្រូវគេបញ្ជូនឲ្យទៅនៅខៅអ៊ីដាងវិញ ដោយបាននាំយកទាំងសម្ភារៈរបស់ក្រុមជំនុំទៅផង ពីព្រោះបន្ទុកនៃការដឹកនាំក្រុមជំនុំទីនោះត្រូវធ្លាក់មកលើខ្ញុំទាំងស្រុង ។

## មូលហេតុដែលនាំឲ្យខ្ញុំទៅជាអ្នកនិពន្ធបទចម្រៀងថ្វាយព្រះ

កាលខ្ញុំសិក្សាក្នុងមធ្យមភូមិ ខ្ញុំបានរៀនអក្សរភ្លេងចេះល្មមរៀបបទភ្លេងបានខ្លះៗ តែខ្ញុំបានយល់ថាឥតប្រយោជន៍បានជាខ្ញុំឈប់ទៅ ។ ចំណោះរបស់ខ្ញុំខាងលេងភ្លេង គឺគ្មានជំនាញលើប្រដាប់ណាមួយសោះ ខ្ញុំអាចលេងបានតែបន្តិចបន្តួចប៉ុណ្ណោះ ។ ចំពោះសាច់ចម្រៀងខ្ញុំអាចច្រៀងបានឥតទាស់ ហើយឥតឲ្យខុសពីលំនាំភ្លេងទាល់តែសោះ ដោយហេតុនេះហើយ បានជាខ្ញុំអាចលើកបទចម្រៀងកើត យោលទៅតាមភាពជំនាញខាងកំណាព្យរបស់ខ្ញុំ ។ កាលឃើញខ្ញុំអាចកូតវីយ៉ូឡុងកើត បងស្រីអាលិសកុំប៉ាំងប្រគល់វីយ៉ូឡុងពីស្រុកចិនមួយដល់ខ្ញុំ ហើយយកទំនុកច្រៀងមួយបាច់ធំមកឲ្យខ្ញុំជួយរើសសម្រាប់ក្រុមជំនុំខ្មែរច្រៀង ។ បទចម្រៀងដែលអាលិសយកទៅឲ្យខ្ញុំ ជាមូលហេតុទាញនាំឲ្យខ្ញុំចាប់តែងបទចម្រៀងឡើង ពីព្រោះខ្ញុំពិនិត្យទំនុកទាំងអស់ដែលអ្នកខ្លះបានតែងមកឥតមានបទណាសមជាបទរបស់គ្រីស្ទានទេ ។ ជាការគួរឲ្យចាប់អារម្មណ៍ចំពោះការលើកបទចម្រៀងដែលខ្ញុំធ្វើ ដ្បិតជាការងាយស្រួលរហូតដល់ខ្ញុំរៀបភ្លេងនិងកំណាព្យជាមួយគ្នាបានឡើងដល់ទៅ៥ បទក្នុងថ្ងៃខ្លះ មានទាំងតែងបទភ្លេងថ្មីៗខ្លះផង ។ ចំណោះខាងភ្លេងដែលខ្ញុំបានបោះចោលឈប់រាប់អានជាយូរឆ្នាំណាស់ហើយ ពេលនោះខ្ញុំស្រាវជ្រាវយមកវិញបាន ហើយចម្រើនឡើង ។ គ្រប់បទដែលបានលើកឡើងនោះបានប្រគល់ឲ្យបងស្រីអាលិលកុំប៉ាំងយកទៅវាយអង្គុលីលេខនៅឯទីក្រុងបាងកក រួចពេលនោះ

មានបេសកជនម្នាក់ជាអ្នកជួយសរសេរអក្សរភ្លេងដោយដៃផ្ទាល់ ។ ដើមឆ្នាំ១៩៨៥ សៀវភៅទំនុកខ្មែរបរិសុទ្ធបានបោះពុម្ពផ្សាយ មានបទចម្រៀង ១៦៦ បទតាមបែបខ្មែរនិយម ។

## ផែនការព្រះសម្រាប់ជីវិតខ្ញុំ

ពេលបានត្រឡប់ជាកូនព្រះអង្គ ខ្ញុំបានឆ្លុះបញ្ចាំងឃើញក្នុងព្រះបន្ទូលអំពីដំណើរជីវិតរបស់ខ្ញុំតាំងពីតូចរហូតមក គឺថាជីវិតខ្ញុំត្រូវនៅក្នុងព្រះហស្តរបស់ព្រះទាំងស្រុង ។ កាលខ្ញុំអាយុប្រហែល៦ ឬ៧ឆ្នាំ ខ្ញុំបានធ្លាក់ពីលើរទេះដឹកកណ្តាប់ស្រូវដែលបរឆ្លងភ្លឺស្រែ ។ ខ្ញុំចាំហេតុការណ៍នោះច្បាស់ឥតភ្លេច ។ ពេលកង់រទេះឡើងលើភ្លឺស្រែពីម្ខាងទៅម្ខាង នោះខ្លួនខ្ញុំត្រូវយោលជាខ្លាំងទៅខាងស្តាំ ដល់កង់ឆ្វេងឡើង ហើយធ្លាក់ចុះគ្រឹប ខ្លួនខ្ញុំត្រូវយោលទៅខាងឆ្វេងយ៉ាងខ្លាំង របូតធ្លាក់រះគូថមេគោទៅក្រោមរទេះ ករបស់ខ្ញុំនៅចំកង់រទេះឃ្លាតពីគ្នាប៉ិនម្រាមដៃ បើកង់នោះវិលតែមួយក្រឹតទៀតខ្ញុំត្រូវស្លាប់ដោយដាច់ក ។ ពេលខ្ញុំធ្លាក់ចុះដល់ដល់ដី មេគោទាំងពីរឈប់នឹងថ្កល់ មិនទាំងបក់កន្ទុយផង រទេះឥតកំរើកសោះរហូតដល់ម្តាយរបស់ខ្ញុំលើកខ្ញុំចេញផុតពីគ្រោះថ្នាក់ ។ ហេតុការណ៍កើតឡើងដល់រូបខ្ញុំ ស្ទើរនឹងរត់ដួលបន្តិចបន្តួចប៉ុណ្ណោះ ហើយក៏ឥតដឹងដែរថា ព្រះជាម្ចាស់បានចាត់ទេវតាទ្រង់ឲ្យមកតាមថែរក្សាខ្ញុំ គឺទេវតានោះបានទប់គោមិនឲ្យទៅមុខ ទប់រទេះឲ្យឈប់នឹងថ្កល់ក្នុងពេលខ្ញុំធ្លាក់ ។ ក្នុងពេលខ្ញុំដឹងហេតុនៃជីវិតខ្ញុំបានគង់វង់ នោះខ្ញុំថ្លែងសរសើរព្រះអង្គ ទាំងអរព្រះគុណជាខ្លាំង ពីព្រោះទ្រង់ពិតជាមានផែនការសម្រាប់ជីវិតខ្ញុំមែន ។ មានហេតុការណ៍ច្រើនទៀតកើតឡើងក្នុងជីវិតខ្ញុំ តែហេតុការណ៍ក្នុងគ្រា៣ឆ្នាំ៨ខែនៃសម័យខ្មែរក្រហមក៏ខ្ញុំចាប់អារម្មណ៍ណាស់ដែរថា បើព្រះអង្គមិនបានរក្សាជីវិតខ្ញុំទុកទេ ខ្ញុំស្លាប់ពេលនោះរួចបាត់ទៅហើយ ។

កាលនៅក្នុង ឆ្នាំ១៩៧៦ ខ្ញុំដេកតែក្នុងពេទ្យឥតថ្នាំ សល់តែកូន

ស្រីច្បងមួយដែលថែរក្សាខ្ញុំ លើកលាមកខ្ញុំដែលជុះដាក់ក្នុងឆ្នាំងចាស់មួយទៅចាក់ចោល ។ មនុស្សស្លាប់ជុំវិញខ្ញុំរាល់ថ្ងៃ ពេលនោះខ្ញុំស្មានក្នុងខ្លួនខ្ញុំថា យ៉ាងយូរណាស់៥ថ្ងៃទៀត គេសែងខ្មោចខ្ញុំយកទៅកប់ដូចគេដែរ ដ្បិតពីត្រឹមចង្កេះចុះក្រោមរាប់ទុកជាខ្មោច នៅសល់តែដៃអាចចាប់តោងដើមអង្កុយជុះពេលឈឺពោះរាកមួលខ្លាំង ។ មានមនុស្សម្នាក់ចេះទាយ ហើយទាយឲ្យគេនៅជិតខ្ញុំ ។ ខ្ញុំនៅសល់វ៉ែនតាស្រទុំមួយ ក៏មានចិត្តចង់ឲ្យទៅគាត់ ដើម្បីឲ្យគាត់ទាយលេង ។ ខ្ញុំមិនជឿគ្រូទាយទេ គ្រាន់តែឲ្យគាត់ទាយលេងមើលថា តើខ្ញុំស្លាប់កាលណា ។ គាត់មើលមុខខ្ញុំ រួចចាប់ដៃខ្ញុំមើលក្រយៅ ទាយថាមិត្តឯងមិនស្លាប់ទេ ២ឬ៣ថ្ងៃទៀត មានគេនាំទៅទិសខាងកើតឲ្យបានជា ។ តែខ្ញុំឆ្លើយថា ខ្ញុំប៉ាន់មើលខ្លួនខ្ញុំយ៉ាងយូរ៥ថ្ងៃទៀតខ្ញុំស្លាប់ហើយ ម៉េចក៏ថាខ្ញុំត្រូវរស់ ខ្ញុំឥតជឿទេ ។ ដូចគាត់ថាមែនគឺ២ថ្ងៃក្រោយមក មានឡានពីពេទ្យបាត់ដំបងឡើងទៅស្នើរបន្លែពីសហករណ៍ភ្នំប៉ាដាក ហើយសួររកអ្នកឈឺធ្ងន់ ។ ខ្ញុំក៏សំពះសុំគេចុះឈ្មោះទៅពេទ្យផង តែគេថាមិត្តឯងឥតឈឺធ្ងន់ទេ ខ្ញុំក៏អង្វរគេដោយប្រាប់គេ តាមដំណើរ បានជាគេយល់ព្រមទទួលលើកទៅដាក់លើឡាន ។ តាមពិតខ្ញុំតោងវាឡើងឡានខ្លួនឯង ដ្បិតបើបណ្តោយឲ្យគេលើកខ្ញុំឡើង ខ្ញុំត្រូវដាច់ខ្យល់ស្លាប់ដោយងងឹតមុខខ្លាំង ឯដង្ហើមស្ទើរផុតម្តងៗ ។ កាលបានទៅដល់ពេទ្យ នោះជម្ងឺរាកមួលក៏ជាទៅ តែនៅទន់ជង្គង់ ដើរឡើងដីទេរ និងចោតដោយលំបាក ។ ចេញពីពេទ្យបាត់ដំបង ទៅសុំជ្រកនៅភ្នំក្រពើ ។ មេកងសកម្មការរបស់របស់ខ្ញុំឲ្យខ្ញុំភ្ជួររាស់តែលើដីគោក និងដីចំការ ។ បើពេលនោះគេឲ្យខ្ញុំចុះធ្វើការ លុយភក់ផុងដូចអ្នកឯទៀត ខ្ញុំពិតជាគ្មានជីវិតមកទល់សព្វថ្ងៃនេះទេ ។ ហេតុនេះខ្ញុំចេះតែអរព្រះគុណព្រះ ដោយទ្រង់បណ្តាលឲ្យគេមានចិត្តមេត្តាដល់ខ្ញុំកាលឃើញខ្ញុំខ្សោយ ។ តើគ្រូទាយអាចដឹងអនាគតខ្ញុំបានដែរឬទេ? ទេវតានៃព្រះនាំមាត់ឲ្យនិយាយសម្រាប់កម្លាចិត្តខ្ញុំមិនឲ្យស្រយុតចុះដល់ស្លាប់ទេដឹង? ខ្ញុំមិនហ៊ានអារកាត់ដំណើរនោះ

ដល់សព្វថ្ងៃ ។

ដំណើរដែលខ្ញុំបានទៅរស់នៅប្រទេសអូស្ត្រាលី គឺជាសេរីភាពទូលំទូលាយដល់ខ្ញុំក្នុងកិច្ចការបំរើព្រះអង្គខាងផ្នែកបទចម្រៀង ផ្ទុយទៅវិញបើខ្ញុំទៅនៅសហរដ្ឋអាមេរិក តាមដែលបងប្អូនជាច្រើន ខំធានាខ្ញុំយកទៅ ខ្ញុំជឿថា សៀវភៅទំនុកខ្មែរបរិសុទ្ធត្រូវចប់ត្រឹមបទលេខ១៦៦ ។ មើលចុះគ្រាន់តែសៀវភៅចាប់ផ្តើមចូលរោងពុម្ព ខ្ញុំក៏មានឈ្មោះចេញទៅប្រទេសទី៣តែម្តង បានជាខ្ញុំជឿជាក់ថា ព្រះបានធ្វើការនេះតាមដៃខ្ញុំ ព្រះអង្គទុកខ្ញុំនៅក្នុងជំរំអស់រយៈពេល៦ឆ្នាំ ទាល់តែផែនការរបស់ព្រះបានសម្រេច ។ នៅអូស្ត្រាលី ព្រះអង្គតាមផ្គត់ផ្គង់ខ្ញុំជាសម្ភារៈទំនើប សម្រាប់កែលំអបទចម្រៀង ដើម្បីឲ្យសៀវភៅរបស់ព្រះអង្គបានប្រសើរឡើង គឺកុំព្យូទ័រ ប្រូក្រាមភ្លេង អក្សរខ្មែរ ជាហេតុឲ្យខ្ញុំមានកម្លាំងធ្វើតទៅទៀត តែងបទភ្លេងតទៅទៀត ដរាបដល់សៀវភៅដែលមាន១៦៦បទ ឡើងទៅជា៣០៣បទ ជាទំនុកដែលខ្មែរចូលចិត្តច្រៀងជាងទំនុកប្រែពីបរទេស ។

ខ្ញុំអស្ចារ្យក្នុងចិត្តកាលព្រះបើកសម្តែងឲ្យឃើញពាក្យក្នុងទំនុកជាច្រើនដែលខ្ញុំបានតែងឡើង មានន័យជ្រៅ ហើយទូលាយ ។ បទចំរៀងលេខ១២៦ " បើខ្ញុំស្គាល់ព្រះតាំងពីក្មេង" កាលខ្ញុំលើកឡើងនោះខ្ញុំយល់ថា បើខ្ញុំបានទទួលព្រះអង្គជាព្រះនៃខ្ញុំនៅក្មេងខ្ចី នោះជាការប្រសើរដល់ខ្ញុំមែនទែន តែមិនប៉ុណ្ណឹងឡើយ គឺខ្ញុំបំរើព្រះអង្គជិត២០ឆ្នាំមកហើយ ក៏នៅតែមិនស្គាល់ព្រះអង្គទៀត ដ្បិតមិនស្គាល់ព្រះហឫទ័យទ្រង់ មិនស្គាល់ការដឹកនាំរបស់ព្រះអង្គ ធ្វើអ្វីតាមតែតម្រិះប្រាជ្ញាខ្លួនជាហេតុឲ្យខ្ញុំរស់ដោយខ្វះព្រះចេស្តា ។ ចាប់តាំងពីខ្ញុំទទួលការបើកសម្តែង ឲ្យស្គាល់ការដែលខ្ញុំធ្វើមក ខ្ញុំឈប់ចាត់ទុកបទចម្រៀងទាំងអស់ថាជាស្នាដៃរបស់ខ្ញុំ គឺជាគំនិតរបស់ព្រះវិញ្ញាណបរិសុទ្ធវិញ ឯខ្ញុំគ្រាន់តែជាប្រដាប់សម្រាប់ទ្រង់ប្រើការឲ្យបានចេញជាលទ្ធផលប៉ុណ្ណោះ ។

តាមអំណោយទានជាអ្នកលើកបទចម្រៀង ព្រះអង្គបង្រៀនខ្ញុំឲ្យ

ចេះបែបដែលត្រូវថ្វាយបង្គំព្រះដោយវិញ្ញាណនិងសេចក្ដីពិត ស្គាល់បែបនិយាយទៅកាន់ព្រះដោយផ្ទាល់ៗ បែបលើកតម្កើងព្រះបែបថ្វាយបង្គំព្រះតាមបទចម្រៀង ឲ្យស្គាល់ប្រភេទនៃបទចម្រៀងដែលមានការចាក់ប្រេងតាំងឡើង គឺព្រះវិញ្ញាណសណ្ឋិតនៅក្នុងបទចម្រៀង ដែលកាលណាច្រៀងឡើងមានអំណាច ច្រៀងឡើងលេចចេញឲ្យឃើញវត្តមាននៃព្រះច្រៀងឡើងអ្នកដែលមានទុក្ខព្រួយត្រូវរសាយ ច្រៀងឡើង អ្នកដែលកំពុងឈឺបានជា ។ គ្រាចុងក្រោយនេះ ខ្ញុំមិនតែងបទតាមបែបមុនទៀតទេ គឺលើកកំណាព្យប្រើតែពាក្យនិយាយទៅកាន់ព្រះអង្គផ្ទាល់ពាក្យប្រាស្រ័យជាមួយព្រះដោយស្និទស្នាល ដ្បិតព្រះអង្គបង្ហាញឲ្យខ្ញុំដឹងច្បាស់ថា បើនៅចំពោះវត្តមានព្រះអង្គ ហេតុអ្វីក៏មិននិយាយរកព្រះអង្គ ម្ដេចមិនសរសើរព្រះអង្គតែម្ដង បែរជាស្រែកបញ្ជាតែគ្នាឯង ។ ទំនុកទាំងឡាយណាដែលមានពាក្យបញ្ជា ដូចជាពាក្យ "ចូរ ចូរយើង កុំ " ជាទំនុកគ្មានឥទ្ធិពលនៅចំពោះព្រះឡើយ ។ ទំនុកដែលនិយាយជាបន្ទាល់នោះ មិនមែនជាទំនុកសរសើរឬថ្វាយបង្គំទេ តែជាទំនុកលើកទឹកចិត្ត និងស្អាងជំនឿវិញ ។ ពេលនៅចំពោះវត្តនៃព្រះ ខ្ញុំចូលចិត្តច្រៀងបទចម្រៀងផ្ដោះផ្ដងពីសេចក្ដីស្រឡាញ់ដែលយើងមានចំពោះព្រះ ហើយព្រះមានចំពោះយើងជាយ៉ាងណានោះច្រៀងបទទូលអង្វរ បទថ្វាយសិរីរុងរឿង តែក្នុងពេលចាប់ផ្ដើមការថ្វាយបង្គំវិញ ខ្ញុំច្រៀងបទសរសើរ ហើយក៏មិនដែលប្រើបទដែលមានពាក្យបញ្ជាដែរ គឺនាំគ្នាចូលបែបណាទៅក្នុងទីលាននៃដំណាក់ព្រះ ដោយសប្បាយរីករាយ និងសង្ឃឹម មានភ្លេងហែហម ស្រែកជ័យឃោសសន្ធាប់ខ្លាំងកុំឲ្យរាំងស្កាត់ផ្លូវយើងបាន ។

ខ្ញុំបានតាំងចិត្តបំរើព្រះអង្គដោយផ្ទាល់ ឥតបំរើនិកាយណាមួយឡើយ ហើយក៏មិនចង់បានផលប្រយោជន៍ជាកេរ្ដិ៍ឈ្មោះអ្វីពីការដែលខ្ញុំធ្វើដែរ ។ ក្នុងជម្រៅចិត្តរបស់ខ្ញុំគឺចង់ឲ្យតែព្រះនាមនៃព្រះយេស៊ូ និងព្រះនៃខ្ញុំបានតម្កើងឡើងយ៉ាងខ្ពស់ ដោយសារបងប្អូនលើកតម្កើងព្រះអង្គនៅក្នុង

បទចម្រៀងដែលព្រះអង្គប្រទានដល់បងប្អូនតាមរយៈខ្ញុំ ហើយចង់ឲ្យបងប្អូនគ្រប់គ្នាបានពរពីព្រះអង្គផ្ទាល់ដោយសារចេះលើកតម្កើងព្រះអង្គ ។

ជីវិតចុងក្រោយរបស់ខ្ញុំនេះ ខ្ញុំបានសម្រេចជាស្រេចទាំងប្រាប់ដល់បងប្អូនខ្ញុំជាច្រើនគ្នាថាខ្ញុំសូមរស់ថ្វាយព្រះ សូមធ្វើតាមតែព្រះហឫទ័យព្រះ ដោយលះកាត់ចិត្តខ្លួនឯង ផ្ទុកឈើឆ្កាងខ្លួនដើរតាមព្រះយេស៊ូ តែខ្ញុំជឿច្បាស់ថា ខ្ញុំខ្សោយខ្ញុំមិនអាចធ្វើបានតាមការសម្រេចចិត្តរបស់ខ្ញុំទេ ទាល់តែព្រះវិញ្ញាណបរិសុទ្ធជួយខ្ញុំទាំងស្រុង ដ្បិតខ្ញុំដឹងតាមព្រះបន្ទូល និងតាមការពន្យល់បំភ្លឺពីព្រះវិញ្ញាណថា ដែលបានជាយ៉ាងណានោះ គឺដោយសារព្រះគុណទេ កុំបីអ្នកណាមួយអួតខ្លួន ក៏មិនមែនដោយការខំប្រឹងតាមកម្លាំងខ្លួន ឬការប្រព្រឹត្តិដែរ ។ ដូច្នេះ ដែលខ្ញុំបានទៅជាយ៉ាងណាបានដូចបំណាងរបស់ខ្ញុំសុំ ឬ មិនបាននោះស្រេចលើព្រះអង្គតែប៉ុណ្ណោះ ។

HONEYCOMB 2/3 (July 2001): 100–105



*SAM Sarin*

# Meet Sam Sarin

I became an orphan at the age of five. In 1955, at the age of fifteen, I went to live in one of the pagodas in Phnom Penh in order to pursue my studies. As I did not obtain a high school diploma, it was very difficult to find a job that would enable me to make a living. So as a poor young man I quit my studies in 1963 and moved to the countryside in Battambang province. There I met my wife and married in 1965. We settled in Pailin until Cambodia fell under the rule of the Khmer Rouge. We were then deported to Phnom ProrDark where my wife and my three children died in 1976.

In late 1979 I went to Kao I Dang camp in Thailand where Jesus Christ revealed himself to me and I accepted him as the creator of the universe. I first heard his name in 1955, but assumed that he was just another one of the gods of the religions. I started my new life in Christ in January 1980, and after baptism in March, was deported to another refugee camp, Sakeo II. In early 1981 I attended a short-term course at a Bible School in Sakeo II and was chosen as church elder. I applied for immigration to the USA but failed my resettlement interview in the Kamput camp in 1982. In early 1983 I was deported back to Kao I Dang along with some church materials. The leadership role of the church fell on my shoulders entirely.

## How I became a Christian Songwriter and Composer

I studied music for a while and had enough understanding to compose some songs while still a student, but I thought it was not good enough and decided to give it up. I did not even continue singing. I was not really good at playing any one instrument, but played a little bit of this and a little bit of that. However, I was quite good at sight-reading while singing. This allowed me to compose songs according to my skill, and arrange words to notes. Miss Alice Compain, with whom I had become acquainted, knew that I could play violin, and out of the goodness of her heart bought me one that had been made in China. Together with this she included a large number of songs and asked me to choose some for use in the Khmer church. Some of the songs that Alice gave me prompted me to compose new ones, because when I checked them I found that they were not suitable for Christian singing. I found it interesting to discover that it was easy for me to put music to poetry. Some days I would compose up to five and also add new melodies to some on the same day. I found that although I had not used my musical knowledge for so many years, much of it I recalled and I progressed strongly and quickly. All the songs that I composed I gave to Sister Alice to type in Bangkok where a missionary helped to write the notes by hand. In early 1985 a Khmer hymnal was published containing 166 Khmer folksongs.

## God's plan for my life

When I became a child of God, I reflected on the words of God on my life since I was very small. I knew that my life was in God's hand completely. When I was around six or seven years old I fell from a cart that was loaded with rice bundles. We were crossing a dike at the time. I remember that fact clearly. When the right wheel of the oxcart rolled up the dike, it rocked me to the right. When the left wheel rolled up the dike, it gave a big swing and tossed me to the left until I fell down onto the buttock of the left cow and then to the ground. My neck was very close to the wheel—about one finger's width away. If the wheel had moved

only a little my head would have been chopped off. As I fell to the ground, both cows suddenly stood still, not even moving their tails until my mother removed me from that dangerous position. This accident did not cause me any injuries. I did not know that God sent his angel to look after me. The angel even stopped the cows from moving forward thus saving me from a certain death. I give him praise and thanks when I recall this because I know he really has a plan for my life.

Many things occurred in my life, but one event that stands out above them all is the one that occurred three years and eight months into the reign of the Khmer Rouge. Had God not preserved my life I would have died during that dark period. In 1976 I was hospitalized in one of the Khmer Rouge hospitals where there was neither medicine nor food. My eldest daughter, who was the last remaining member of my family, took care of me during the time I was sick. Many people were dying around me everyday.

When I became worse, I said to myself that in five day's time they will carry my body to be buried like the rest, as I was paralyzed from the waist down. I could only move my hands to hold my body. I passed stools very frequently because I had severe dysentery. There was a fortuneteller who "prophesied" for somebody nearby me. I had one pair of sunglasses left that I wanted to give him as payment so that he could predict my fortune. I did not believe in fortune telling, but I just wanted to ask him to "prophesy" for fun. I asked him if he knew when I would die. He looked in my face and held my hand, looking for the answer in my palm and then he said, "You are not going to die. In two or three days you will be taken east and then be healed." But I said to him that I thought I would die in five days' time; I didn't believe him.

But like he said, two days later a truck from Battambang hospital arrived at Phnom Prordak, where I lived, to ask for vegetables and to take some seriously ill people for treatment in Battambang. I pleaded with the head nurse by bringing my palms together in front of my chest in a gesture of respect, asking for a favor to take me as well. She looked at me and said, "Comrade, you are not very sick. We only take the serious ones." But I

insisted, telling her how I felt. She accepted my plea and took me with her. Two nurses carried me to the truck, but I was almost out of breath when they tried to make me stand. My eyes looked like bright green stars. I asked them to put me down and crawled to climb up the truck by myself. When I arrived in the hospital my diarrhea and dysentery were gone but my knees were still very weak. I walked up to the higher ground with difficulty.

I was discharged from hospital in Battambang and went to stay in Phnom Krapeu. The group leader of my mobile team allowed me to plow in dry land. If they sent me to work in the muddy field like the others, I might not be alive today. Therefore I always praise the Lord for softening the heart of my group leader to show mercy on me while I was so weak. Could the fortuneteller predict my future? Maybe the Lord's angel put his word in that fortuneteller's mouth to encourage me to have hope? I am unable to answer that question even until today.

My resettlement in Australia provided me a broad freedom to serve the Lord in the ministry of songwriting. By contrast, if I had resettled in the United States, as many brothers and sisters had tried to help me to do, I believe that the Khmer hymnal may have ended up with only 166 songs. You see, only when the enhanced hymnal was taken to the printing house was my name chosen for resettlement in a third country. I believe that God let me stay in the refugee camp for six years until his plan was fulfilled. In Australia God provided me with hi-tech equipment to produce hymnbooks of better quality, such as a computer, music programs, and a Khmer font that enabled me to produce more songs. The number of Khmer songs in the book increased from 166 to 303: It is now easier for Christian Khmers to sing these songs than those that have been translated from foreign languages.

I was amazed at the broad and deep meaning God revealed to me in the songs I wrote. As I composed song number 126, "If I Knew God When I was Young," I realized that if I had accepted God when I was young it would have been fantastic! But even though I have served the Lord for twenty years, I still do not know him enough, nor his will or his leading. That is why I lived without

God's power in my life. God has impressed on me not to treat the hymnbook as my personal accomplishment, since the Holy Spirit encouraged my writing, and I was only the instrument or vessel that he used.

Through the gift of song composing, God taught me how to worship him in spirit and in truth and how to communicate directly to him through praise and worship songs. He showed me the kind of song that is anointed by the Holy Spirit. When this kind of song is sung it is powerful and the presence of the Lord is known. The weary will be released. The sick will be healed. Now I do not compose songs in the way that I used to. I use poetry to speak directly to God in words that communicate to him more closely. For he showed me clearly that if we are in the presence of the Lord why not speak to him and praise him? Why only speak to each other—shouting and delivering commands among ourselves? The songs that follow our own words have no impact in the presence of the Lord.

Some songs that speak about our testimony do not give him praise or glory, but rather encourage us, edify us, and build up our faith. In the presence of the Lord I like to sing in such a way as to express our love for him and the love of God towards us. We may sing songs of intercession, but only at the beginning of a worship service. As we enter the Lord's presence we should use only songs that praise him as we enter into his court with joyful hearts and with hope. We also praise with music and shouts of victory over the enemy (Psalm 100:1, 4).

I intend to serve God, not a denomination. I do not wish any fame from what I am doing. All I want is for the name of Jesus to be lifted up on high through the songs that God gives to brothers and sisters through me. I want you all to be blessed as you sing and praise him.

Finally, I want to tell my brothers and sisters that I want to live for God, do his will, deny myself carry my cross, and follow him every day. But I believe that I am weak and cannot fulfill all that I have decided to do in my own strength unless the Holy Spirit helps me. I depend only on the Word of God and the enablement of

the Holy Spirit and his grace. I do not depend on my own abilities. "'Not by might nor by power, but by my Spirit,' says the Lord."